សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit et des Science Economique

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២១ ដល់ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **១. សេន ណារីន**

**២. សុន គឹមហុង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាប័ត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Science Economique**

**Royal University of Law and Economic**


# សារណាបញ្ចប់ការសិក្សា

## ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌
## ក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២១ ដល់ថ្ងៃទី  ១៣ ខែសីហា ឆ្នាំ ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **១. សេន ណារីន**

**២. សុន គឹមហុង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ ឈ្មោះ **សេន ណារីន** និង នាងខ្ញុំឈ្មោះ **សុន គឹមហុង** ដែលជាសិស្សនិស្សិតបរិញ្ញាប័ត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២២ ក្នុងឆ្នាំសិក្សា ២០១៧-២០២២ ។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

**លោកឪពុក និង អ្នកម្តាយ** របស់យើងខ្ញុំដែលធ្វើការ ចំណាយសព្វគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាង ទាំងស្មារតី និងសម្ភារៈ ព្រមទាំងបានខិតខំប្រឹងប្រែងដើម្បីកូនបានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ មិនត្រឹមតែប៉ុណ្ណោះ លោកទាំងពីបានគង់នៅជាម្លប់ដ៏ត្រជាក់ដល់កូនចៅដើម្បីឆ្ពោះទៅរកភាពជោគជ័យ និង ក្តីស្រមៃទៅថ្ងៃអនាគត ។

**ឯកឧត្តម លុយ ចន្ធ្នា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំពង្រីកនូវចំណេះដឹង និងបង្កើតនូវជំនាញតាមរយៈការចងក្រង តាក់តែងកិច្ចការស្រាវជ្រាវសារណាដើម្បីបញ្ចាប់ការសិក្សាថ្នាក់បរញ្ញាបត្រនេះឡើង។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **ថ្នាក់ដឹកនាំនៃសកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំគិតគូរដល់សិស្សានុសិស្ស ទាំងឡាយ នូវចំណេះដឹង អនាម័យ ជាសុខភាព និងសុវត្ថិភាពដល់សិស្សានុសិស្សទាំងឡាយ ។

ជាពិសេសជាងនេះទៅទៀត យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សាដល់រូបខ្ញុំទាំងពីរនាក់។ លោកស្រីសាស្ត្រាចារ្យបានផ្តល់ឱកាសដល់យើងខ្ញុំទាំងពីរនាក់ ក្លាយទៅជាចំណែកនៃកាតព្វកិច្ចមួយរបស់លោកស្រី ក្នុងការផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត និងត្រួសត្រាយផ្លូវ ឲ្យក្លាយចេញទៅជាផ្លែផ្កាដ៏ស្រស់បំព្រង ។

ជាចុងក្រោយយើងខ្ញុំសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តសិទ្ធិនៅក្នុងលោក សូមឲ្យអ្នកមានគុណ មាតាបិតា និងថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាស្ត្រាចារ្យដែលបានយកចិត្តទុកដាក់ ក្នុងការអប់រំទូន្មានប្រៀនប្រដៅ ដល់យើងខ្ញុំទាំងពីរនាក់ ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

នាងខ្ញុំឈ្មោះ **សេន ណារីន** និងនាងខ្ញុំឈ្មោះ **សុន គឹមហុង** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី ២២ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** មានកិត្តិយសនៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងការតាក់តែង ចងក្រងនូវប្រធានបទមួយនៃសារណាបញ្ចប់ការសិក្សាស្តីពី «**ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ**» ដែលទាក់ទងទៅនឹងការសិក្សាលើមុខវិជ្ជានីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ដែលបានសិក្សាកន្លងមក ដើម្បីយកជាទ្រឹស្តីនៃមុខវិជ្ជាទាំងអស់នេះមកធ្វើជាការចងក្រងជាស្នាដៃនេះឡើង។

ម្យ៉ាងវិញទៀត មូលហេតុដែលជម្រុញឲ្យយើងខ្ញុំស្រាវជ្រាវអំពីប្រធានបទ «**ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ**» នេះឡើងគឺដើម្បីទុកជាឯកសារជំនួយស្មារតី សម្រាប់និស្សិតទាំងឡាយ ដែលមានគោលបំណងស្វែងយល់ និងសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។ បន្ថែមទៅទៀត ពិព្រោះយើងខ្ញុំយល់ឃើញថា ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នកច្បាប់ ក្នុងការសិក្សាស្រាវជ្រាវស្វែងយល់ដោយសារតែបុគ្គលណាក៏ដោយតែងតែមានបញ្ហាជៀសមិនផុតឡើយជាពិសេសទាក់ទងទៅនឹងជម្លោះហិង្សារំលោភ។ល។ មិនត្រឹមតែប៉ុណ្ណោះចំពោះប្រជាពលរដ្ឋក៏មានសារៈសំខាន់ចំពោះពួកគាត់ផងដែរ ដោយសារតែអាចធ្វើ ឲ្យពួកគាត់បានស្វែងយល់អ្វីទៅជាការបទល្មើស ដំណើរការស៊ើបអង្កេត។ ដោយសារតែពួកយើងមានរយៈពេលនៃការស្រាវជ្រាវមានកំណត់ ដូចនេះលទ្ធផលនៃការស្រាវជ្រាវនេះពិតជាមានកង្វះខាត ចន្លោះប្រហោងផ្សេងៗ ដោយមិនបានវិភាគឲ្យល្អិតល្អន់ គ្រប់ជ្រុងជ្រោយនោះទេ។

យើងខ្ញុំសង្ឃឹមយ៉ាងខ្លាំងថា តាមរយៈការសិក្សាស្រាវជ្រាវពីការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ពិតជាបានចូលរួមក្នុងការកាត់បន្ថយនូវជម្លោះ និងបញ្ហាគ្រួសារនានា តាមរយៈការចែករំលែកនូវចំណេះដឹងច្បាប់ទៅដល់ប្រជាពលរដ្ឋក្នុងសង្គម ដើម្បីឲ្យសង្គមមួយ ឬប្រទេសមួយពោរពេញទៅដោយការអត់ឱនយោគយល់ អធ្យាស្រ័យគ្នា ជាពិសេសនៅក្នុងរង្វង់គ្រួសារ។

យើងខ្ញុំសូមសំដែងការត្រេកអរជាអនេកក្នុងការរៀបរៀងកិច្ចការស្រាវជ្រាវនេះជាឯកសារសំរាប់ការសិក្សាឡើងហើយក៏សូមខន្តីអភ័យទោសជាមុននូវរាល់កំហុសឆ្គងនិងរាល់ចំណុចខ្វះខាតទាំងឡាយដែលកើតឡើងដោយអចេតនាដូចជា ពាក្យពេចន៍ អក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ ផងដែរ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលបានបង្ហាត់បង្រៀន និងពន្យល់ណែនាំដោយយកចិត្តទុកដាក់ និងសូមជូនពរឱ្យលោកគ្រូជួបតែ ពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លាងឃ្លាតឡើយ។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃការស៊ើបអង្កេត**

**ផ្នែកទី១៖ អត្ថន័យនៃការស៊ើបអង្កេត** ........ ៣

១.ការស៊ើបអង្កេត ........ ៣

២.តួនាទីនៃភស្តុតាង ........ ៤

៣.មូលហេតុនៃការស៊ើបអង្កេត ........ ៤

៤.ដំណើរការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ ........ ៥

៥.ដំណាក់កាលនៃការស៊ើបអង្កេត ........ ៥

៦.អាជ្ញាធរទទួលបន្ទុកស៊ើបអង្កេត ........ ៦

**ជំពូកទី២**

**នគរបាលយុត្តិធម៌**

**ផ្នែកទី១៖ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌** ........ ៧

**កថាខណ្ឌទី១៖ មន្ត្រីនគរបាលយុត្តិធម៌** ........ ៧

១. លក្ខខណ្ឌដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ........ ៨

១.១. ការទទួលបានតាមរយៈឋានន្តរស័ក្ក ........ ៨

១.២.ការទទួលបានតាមរយៈការប្រលងប្រជែញ ........ ៨

១.៣. ការទទួលបានដោយស្វ័យប្រវត្តិ ........ ៩

**កថាខណ្ឌទី២៖ សមត្ថកិច្ចដែនដី និងការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌** ........ ១១

២.១. សមត្ថកិច្ចដែនដី ........ ១១

២.២. សមត្ថកិច្ចសម្ភារៈ ........ ១២

២.៣. អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................ ១២
២.៤. ការពន្លាតដែនសមត្ថកិច្ច........................................ ១២
២.៥. កម្មវិបាកនៃការមិនគោរពវិធានបញ្ញត្តិ ........................................ ១៣
**ផ្នែកទី២.ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌** ........................................ ១៣
១. ការទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌........................................ ១៣
២ .ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌........................................ ១៣
៣. បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌........................................ ១៤
៤. សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ........................................ ១៤
៥. កំហុសដែលត្រូវបានប្រព្រឹត្តិក្នុងពេលបំពេញមុខងារ ........................................ ១៥
**ផ្នែកទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទានពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន** ........................................ ១៥
១. ការទទួលបាននូវនីតិសម្បទានតាមរយៈច្បាប់ដោយឡែក ........................................ ១៥
២. ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ........................................ ១៦
៣. សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ........................................ ១៧
៤. កំហុសរបស់មន្ត្រីរាជការ និងភ្នាកងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ............. ១៨

## ជំពូកទី៣

## នីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌(ករណីបទល្មើសជាក់ស្តែង)** ................ ២០
**កថាខណ្ឌទី១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ........................................ ២០
១.១. និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ........................................ ២១
១.២. កិច្ចនានានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង........................................ ២១
១.៣. វិធានដំបូងក្នុងការស្រាវជ្រាវនៃបទល្មើស........................................ ២២
១.៤. ការឆែកឆេរ........................................ ២២
១.៥. ការបិទស្លាកបោះត្រាលើវត្ថុតាងដែលចាប់យក........................................ ២៣

១.៦. ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ........................................ ២៤
១.៧. កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយ ........................................ ២៤
១.៨.ការបញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតជាក់ស្ដែង ........................................ ២៥
១.៩. ការឃាត់ខ្លួន ........................................ ២៥
១.៩.១. បែបបទនៃការឃាត់ខ្លួន ........................................ ២៥
១.៩.២. រយៈពេលនៃការឃាត់ខ្លួន ........................................ ២៦
១.៩.៣.ការឃាត់ខ្លួនចំពោះអនីតិជន ........................................ ២៧
១.៩.៤.សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន ........................................ ២៧
១.៩.៥.បញ្ជីនៃការឃាត់ខ្លួន ........................................ ២៨
១.៩.៦. កំណត់ហេតុសរុបនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................ ២៩
១.១០ ការបញ្ជូនខ្លួន ........................................ ៣០
១.១០.១. ការបញ្ជូនខ្លួនបុគ្គលដែលសង្ស័យ ........................................ ៣០
១.១០.២.រយៈពេលនៃការបញ្ជូនខ្លួន ........................................ ៣០
**កថាខណ្ឌទី១.វិធានទាក់ទងនឹងការស៊ើបអង្កេតជាក់ស្ដែង** ........................................ ៣១
១.១. ចិរវេលានៃការស៊ើបអង្កេតជាក់ស្ដែង ........................................ ៣១
១.២.ការហាមឃាត់មិនឱ្យស្ដាប់ចម្លើយដោយឯកឯង ........................................ ៣១
១.៣. ការបញ្ជូនកំណត់ហេតុ វត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ........................................ ៣១
១.៤.មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ ........................................ ៣២
**កថាខណ្ឌទី២៖ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្ដែង** ........................................ ៣៣
២.១ ការបើកការស៊ើបអង្កេតបឋម ........................................ ៣៣
២.២ វិធានទាក់ទងនឹងការស៊ើបអង្កេតបឋម ........................................ ៣៣
២.៣.មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ ........................................ ៣៤
២.៤.ការឆែកឆេរ ........................................ ៣៤
២.៥ ការបញ្ជាឱ្យចូលខ្លួន ........................................ ៣៥

២.៦ ការឃាត់ខ្លួនជនសង្ស័យ........................................................................................................៣៦
២.៧. កំណត់ហេតុស្តីពីការស្រង់ចម្លើយ ..........................................................................................៣៦
២.៨. ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន ........................................................................៣៦
**កថាខណ្ឌទី៣៖ ការបញ្ចប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌** .................៣៧
**កថាខណ្ឌទី៤៖ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌** ....................................៣៧
៤.១ ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួន ..........................................................................៣៨
៤.២ ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ .......................................................៣៨
៤.៣ ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនរយៈដីការបញ្ជូន ឬសាលដីការបញ្ជូន...................................៣៨
៤.៤ ការធ្វើជាសាក្សីរបស់មន្ត្រីនគរបាលយុត្តិធម៌ ..............................................................................៣៩
៤.៥ ការធានាសណ្តាប់ធ្នាប់នៃសវនាការ...........................................................................................៣៩
៤.៦ ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ........................................................................៣៩
៤.៧ ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ..........................................៣៩
៤.៨ ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ............................................... ៤០
**សេចក្តីសន្និដ្ឋាន**.....................................................................................................................**៤១**
**អនុសាសន៍**........................................................................................................................... **៤៣**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

គេតែងតែងនិយាយថាទីណាមានមនុស្សទីនោះរមែងតែកើតបញ្ហាជាហូរហែរ មិនថាប្រទេសណានោះទេរមែងតែងតែកើតមាននូវបញ្ហា ឬកើតមាននូវជម្លោះផ្សេងៗដែលកើតឡើងរវាង ភាគី និងភាគី ដែលជាហេតុ នាំឱ្យមានការចងក្រងនូវច្បាប់ជាច្រើនសម្រាប់អនុវត្ត នៅក្នុងបណ្តាប្រទេសនានានៅលើសាកលលោកយើងនេះ។ ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ ដោយបានស្វែងយល់ពីផលលំបាកដែលបានកើតឡើង និងចំណោទបញ្ហាជាច្រើនផងនោះ ទើបយើងបានចងក្រងច្បាប់ជាច្រើនផងដែរ នៅក្នុងនោះក៏មានច្បាប់ព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្ត និងគោរពតាមដែលយើងមិនអាចខ្វះបាន ដោយសារតែចោលបញ្ហាមួយចំនួនធំគឺបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌផងដែរ ទើបតម្រូវដោយមានច្បាប់ទាំងនោះជាចាំបាច់។ កាលណាមានបទល្មើសត្រូវតែមាននីតិវិធីក្នុងការដោះស្រាយ។ ក៏ដូចគ្នាផងដែរទៅនឹងបទល្មើសព្រហ្មទណ្ឌក្នុងព្រះរាជណាចក្រកម្ពុជា ត្រូវមាននូវនីតិវិធីព្រហ្មទណ្ឌក្នុងការដោយស្រាយ។

តើអ្វីជានីតិវិធីព្រហ្មទណ្ឌក្នុងព្រះរាជាណាចក្រកម្ពុជា? តើវាជាប់ពាក់ទៅនឹងការដោះស្រាយនូវចំណោទបញ្ហាទាំងនោះយ៉ាងដូចម្តេច?

នីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិ នៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណា ពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសនោះ ទេ។ ជាច្បាប់ដែលសិក្សាអំពីរបៀបរៀបចំអំណាចតុលាការដើម្បីតម្រូវឲ្យសាលាជម្រះក្តីគោរពតាម និងអនុវត្តតាមគោលការណ៍ដែលត្រូវគោរពសិទ្ធិ និងសេរីភាពបុគ្គលក្នុងការឃាត់ខ្លួន ការឃុំខ្លួននិងវិធីផ្សេងៗទៀតដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ដោយអង្គការតុលាការគ្រប់ជាន់ថ្នាក់។

ដូច្នេះនីតិវិធីព្រហ្មទណ្ឌត្រូវបានរៀបចំដើម្បីធានាតុល្យភាពរវាងប្រសិទ្ធភាពនៃការបង្ក្រាប់ ហើយនិងការការពាសិទ្ធសេរីភាពរបស់ជនពាក់ព័ន្ធ។ដំណើរការរឿងក្តីព្រហ្មទណ្ឌយើងអាចចែកជាបួនដំណាក់កាលទៅតាមលំដាប់លំដោយទៅតាមដូចជា៖

- ទី១ គឺការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ ក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា
- ទី២ គឺដំណាក់កាលនៃការចោទប្រកាន់ដែលអនុវត្តដោយព្រះរាជាអាជ្ញាដែលធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើង ដំណាក់កាល
- ទី៣ គឺធ្វើការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ហើយដំណាក់កាល
- ទី៤ គឺដំណាក់កាលជម្រះដែលធ្វើឡើងដោយយុត្តាធិកាជំនុំជម្រះ៕

ដោយសារតែការសិក្សាទាក់ទងទៅនឹងដំណាក់កាលទាំងបួនខាងលើមានភាពលម្អិតនិងស្មុគស្មាញ ហេតុដូចនេះហើយយើងខ្ញុំនឹងលើកយកតែដំណាក់កាលទី១ គឺ ការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ ក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ប៉ុណ្ណោះមកធ្វើការសិក្សាបន្ថែម។

តើនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតមានលក្ខណៈយ៉ាងដូចម្តេច? ហើយនរណាជាមន្ត្រីនគរបាលយុត្តិធម៌? ចុះអ្វីជាការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌? និងនីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងបទល្មើសព្រហ្មទណ្ឌ?

ដើម្បីឆ្លើយតបនឹងសំណួរខាងលើនេះ យើងនឹងធ្វើការសិក្សាទៅលើ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ ឱ្យបានលម្អិតដែល ទាក់ទងទៅនឹង ទិដ្ឋភាពទូទៅនៃការស៊ើបអង្កេត (ជំពូកទី១) នគរបាលយុត្តិធម៌ ( ជំពូកទី២) មិនតែប៉ុណ្ណោះយើងក៏នឹងសិក្សាទៅលើនីតិវិធីនៃការស៊ើបអង្កេតផងដែរ នៅក្នុងជំពូកទី៣ ។

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃការស៊ើបអង្កេត

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃការស៊ើបអង្កេត

អំពើល្មើសនឹងច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើស ម្យ៉ាងវិញទៀតបទល្មើសព្រហ្មទណ្ឌ ជាអំពើទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ហើយអំពើទាំងនោះ គឺជាការបំពានទៅនឹងច្បាប់ព្រហ្មទណ្ឌ។ បទល្មើសដែលមានការកើនឡើង ឬ ថយចុះវាអាស្រ័យទៅនឹងជំនាញ ឬ សមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងបច្ចេកទេសនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ថាតើការប្រព្រឹត្តទៅស្របតាមវិជ្ជាជីវៈដែរ ឬទេ? ហើយវាស្របទៅនឹងអ្វីដែលមានចែងស្របទៅនឹងច្បាប់ដែរ ឬទេ? ជាក់ស្តែង ការប្រមូលនូវភស្តុតាង ការសាកសួរ ការឃាត់ខ្លួន ការចាប់ខ្លួន ការបញ្ជូនខ្លួន គឺជាបច្ចេកទេសរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីសម្រាប់ធ្វើការស៊ើបអង្កេត នឹងស្វែងរកបទល្មើស ព្រមទាំងបង្ការ និងបង្ក្រាបបទល្មើសនៅក្នុងសង្គម។

ការស៊ើបអង្កេតជាផ្នែកមួយនៃដំណាក់កាលនីតិវិធីព្រហ្ម ទណ្ឌ នៅក្នុងដំណើការពហ្មទណ្ឌចាំបាច់ត្រូវធ្វើក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ ។

ដើម្បីឱ្យកាន់តែច្បាស់ យើងគួរតែយល់អំពី ( ១ )និយមន័យនៃការស៊ើបអង្កេត និងរឿងក្តីព្រហ្មទណ្ឌជាមុនសិន ។

## ផ្នែកទី១.អត្ថន័យនៃការស៊ើបអង្កេត

ការស៊ើបអង្កេត គឺជានីតិវិធីនៃការស្វែងរកពត៌មានត្រឹមត្រូវ ពត៌មានជាក់ស្តែងដើម្បីកំណត់ការពិត ដែលជាបច្ច័យទានដ៏សំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ ជាពិសេសក្នុងបទល្មើសព្រហ្មទណ្ឌ។ ការស៊ើបអង្កេតទាមទារឱ្យធ្វើដោយហ្មត់ចត់ គោរពឱ្យបានត្រឹមត្រូវតាមវិធានច្បាប់ ដែលតម្រូវឱ្យធ្វើការ ស្រាវជ្រាវរហូតទាល់តែរកឃើញចម្លើយថា មានរឿងអ្វីកើត ឡើង? នរណាអ្នកទទួលខុសត្រូវ?

ចំពោះអ្នកដែលមានសម្ថតិកច្ចក្នុងការស៊ើបអង្កេតឬយើងហៅថាអ្នកស៊ើបអង្កេតត្រូវមានចំណេះដឹងខាងច្បាប់ បច្ចេកទេស និងទេពកោសល្យ ទើបនាំឱ្យការស៊ើបអង្កេតនោះប្រព្រឹត្តដោយអព្យាក្រឹតត្រឹមត្រូវ និងយុត្តិធម៌ ទើបឈានដល់ការនាំយកបុគ្គលដែលប្រព្រឹត្ត ខុសក្នុងបទល្មើសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

### ១.ការស៊ើបអង្កេត

ការស៊ើបអង្កេត ជានីតិវិធី និងដំណើរការដ៏ចាំបាច់បំផុតក្នុងដំណើរការស្វែករកនូវមានភាពត្រឹមត្រូវយុត្តិធម៌ក្នុងបទល្មើសព្រហ្មទណ្ឌ ដើម្បីធានាជូននូវភាពច្បាស់លាស់យុត្តិធម៌ មិនតែប៉ុណ្ណោះមិនថាឡើយតែមាន អនុវត្តនៅក្នុងប្រព័ន្ធច្បាប់ Civil Law នៅក្នុងប្រព័ន្ធ Comon Law ក៏ ដូចគ្នា តុលាការព្រហ្មទណ្ឌ មានយុត្តាធិការជំនុំជម្រះ បុគ្គលមួយ ក្នុងរឿងព្រហ្មទណ្ឌ លុះត្រាតែមានការស៊ើបអង្កេតរកឃើញថា មានកំហុសក្នុង

បទល្មើសព្រហ្មទណ្ឌ និងមានសេចក្តីសម្រេច ចោទប្រកាន់ ។ ការបង្កើតវិធានស៊ើបអង្កេត និង អនុវត្តនៅក្នុងដំណើរការព្រហ្មទណ្ឌ គឺដើម្បីធានានូវការ ការពារ កិត្តិយស សេចក្តីថ្លៃថ្នូរ និង អាយុជីវិតរបស់ពលរដ្ឋ មិនឱ្យបុគ្គល ដែលគ្មានកំហុស ត្រូវរងទណ្ឌកម្ម និងត្រូវដោះលែង ឱមានសេរីភាព ។មិនឱ្យបុគ្គលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួចផុតពីការទទួលខុសត្រូវ ។ ដំណើរការការដោយគោរពបានតាមគោលការណ៍សន្មត់ជាមុនថាគ្មានទោស ។ការចោទប្រកាន់ ការឃាត់ ការចាប់ ការឃុំខ្លួន នឹងអាចធ្វើទៅបានដោយអនុលោមទៅតាមច្បាប់ ។

### ២.តួនាទីនៃភស្តុតាង

ភស្តុតាង ត្រូវដើរតួនាទីដ៏សំខាន់នៅក្នុងដំណើរការ នៃការស៊ើបអង្កេត ក៏ដូចជា នីតិវិធីនៃបទល្មើស ។

ភស្តុតាង គឺជាឬសគល់ដ៏មានសារៈសំខាន់ និងជាចំណុចរស៊ើបក្នុងបទល្មើសព្រហ្មទណ្ឌដែលអាចផ្តល់ព័ត៌មានពីហេតុ ការណ៍ ដែលត្រូវស៊ើបអង្កេត អាចមានដូចជា វត្ថុ ស្លាកស្នាម សំណល់ សរីរាង ការសង្កេតរបស់អ្នកស៊ើបអេង្កេត សក្ខីកម្ម របស់សាក្សី ជនរងគ្រោះ ជនសង្ស័យ ឯកសារ និង ការវិភាគ របស់អ្នកជំនាញ ។

### ៣.មូលហេតុនៃការស៊ើបអង្កេត

មូលហេតុដែលនាំឱ្យមានការស៊ើបអង្កេត ព្រោះការស៊ើបអង្កេតជា វិធីសាស្ត្រដែលត្រូវបានសិក្សា និងចាប់ខ្លួនឧក្រិដ្ឋជន។ អ្នកស៊ើបអង្កេតស្វែងរកការបញ្ជាក់ពីវិធីសាស្ត្រ ហេតុផល និងអត្តសញ្ញាណឧក្រិដ្ឋជន និងអត្តសញ្ញាណជនរងគ្រោះ ហើយក៏អាចស្វែងរក និងសួរចម្លើយសាក្សីផងដែរ។ ការស៊ើបអង្កេតឧក្រិដ្ឋកម្ម គឺជាកិច្ចការដែលស្វែងរក ប្រមូល និងប្រមូលភស្តុតាងនៃឧក្រិដ្ឋកម្មសម្រាប់ករណី ឬគោលបំណងជាក់លាក់។
អ្នកស៊ើបអង្កេតស្វែងរកតម្រុយនិងភស្តុតាងដើម្បីកំណត់ថាតើឧក្រិដ្ឋកម្មបានកើតឡើងឬយ៉ាងណា។ ប្រសិនបើឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត អ្នកស៊ើបអង្កេតអាចពិនិត្យមើលសាវតារបស់ជនជាប់ចោទ ហើយព្យាយាមរកឱ្យឃើញថាតើនរណាជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋ។ ភ្នាក់ងារប៉ូលីស និងការអនុវត្តច្បាប់បានប្តេជ្ញាចិត្តក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មគ្រប់បែបយ៉ាង ប៉ុន្តែចំនួនបុគ្គលដែលកំពុងកើនឡើងកំពុងជ្រើសរើសបើកការស៊ើបអង្កេតឧក្រិដ្ឋកម្មផ្ទាល់ខ្លួនរបស់ពួកគេ ដោយមានជំនួយពីអ្នកស៊ើបអង្កេតដែលមានជំនាញវិជ្ជាជីវៈ។ ពួកគេ ប្រតិបត្តិការ ក្នុងច្បាប់ ដើម្បី ស្វែងរក ភស្តុតាងអ្នកស៊ើបអង្កេតផ្នែកការពារឧក្រិដ្ឋជនអាចប្រមូលភស្តុតាងនៃការផ្តន្ទាទោសមិនត្រឹមត្រូវ ឬការចោទប្រកាន់ អ្នកស៊ើបអង្កេតអនុវត្តច្បាប់ច្រើនតែរវល់ជាមួយការងារផ្សេងទៀត។ផ្នែកស៊ើបអង្កេតឧក្រិដ្ឋកម្មអាចមានរយៈពេលខ្លីពេកលើធនធានដើម្បីធ្វើការស៊ើបអង្កេតត្រឹមត្រូវ។ អ្នកស៊ើបអង្កេតឧក្រិដ្ឋកម្មគឺមានភាពខ្ជាប់ខ្ជួនជាងការអនុវត្តច្បាប់ ដូច្នេះពួកគេអាចផ្តល់លទ្ធផលល្អប្រសើរ អ្នកស៊ើបអង្កេតឧក្រិដ្ឋកម្មមិនកំណត់ដោយយុត្តាធិការទេ។ឧក្រិដ្ឋកម្ម គឺជាអំពើដែលមានចេតនា ដែលផ្ទុយនឹងច្បាប់សម្រាប់សហគមន៍។ ការកាត់ក្តីឧក្រិដ្ឋកម្ម ដែលការផ្តន្ទាទោសត្រូវបានបន្តដោយរដ្ឋាភិបាល ខុសពីការកាត់ក្តីរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងបុគ្គលដែលពិភាក្សាអំពីសិទ្ធិរបស់ពួកគេ។ អំពើឧក្រិដ្ឋកម្ម ដូចជា ការរំលោភផ្លូវភេទ ការរំលោភលើរាងកាយ

ឃាតកម្ម អំពើចោរកម្ម ការខូចខាតទ្រព្យសម្បត្តិ និងការបំផ្លិចបំផ្លាញ នឹងអំពាវនាវឱ្យអ្នកស៊ើបអង្កេតប្រមូលភស្តុតាង ដើម្បីអាចធ្វើការចោទប្រកាន់បាន។

### ៤. ដំណើរការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ

ដំណើរការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវប្រព្រឹត្តឡើងជាដំណាក់ៗ តាមការអនុវត្តរបស់មន្ត្រីមានសមត្ថកិច្ច ដើម្បីដំណើរការស៊ើបអង្កេតឈានដល់ការកំណត់នៃបទល្មើស។ ហើយការស៊ើបអង្កេតពាក់ព័ន្ធនឹងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមមួយត្រូវបានប្រព្រឹត្ត។ ហើយថាតើការចាប់ខ្លួនគួរតែត្រូវបានដេញតាម ក្រោយពីធ្វើកោសល្យវិច័យ រួចសមត្ថកិច្ច បាន ប្រមូល វត្ថុតាងនិងកំណត់អត្តសញ្ញាណជនសង្ស័យ ។ បើប្រមូលបានភស្តុតាងគ្រប់គ្រាន់ជនសង្ស័យត្រូវចាប់ខ្លួន ដូច្នេះភស្តុតាងទាំងអស់ដែលប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេតត្រូវបានបង្ហាញដល់តុលាការ ហើយការសម្រេចត្រូវបានធ្វើឡើងទាក់ទងនឹងការដាក់ទណ្ឌកម្ម។ ដើម្បីដែលតែច្បាស់យើងខ្ញុំនឹងធ្វើការបកស្រាយនូវចំណុចខាងក្រោមដូចតទៅះ

### ៥.ដំណាក់កាលនៃការស៊ើបអង្កេត

ដំណាក់កាលដំបូងនៃការស៊ើបអង្កេត ជាដំណាក់កាល ស្វែងរកភស្តុតាងឱ្យបានច្រើន និង ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើ ហើយភស្តុតាងនោះត្រូវតែជាប្រភពដ៏ចាំបាច់ ហើយថាតើភស្តុតាងហ្នឹងនាំទៅរកភស្តុតាងដទៃទៀតដែរឬទេ?

នៅពេលដែលយើងរកឃើញនូវភស្តុតាងហើយនិងចាប់ផ្តើមធ្វើជាឯកសារ ខណៈដែលភស្តុតាងខ្លះទៀតមិនទាន់ទទួលបាននៅឡើយ ហើយមិនត្រូវបឱិតករណីមួយ ដោយចាប់ផ្តើមជាមួយនឹងអ្វី ដែលខ្លួន យល់ថា ជាការពិត ដោយបង្កើតការពិតជាមួយនឹងការវាយតម្ល លំអៀង ឬ ប្រើប្រាស់ភស្តុតាងក្លែងបន្លំ ក្រៅពីត្រូវស្តាប់ភស្តុតាង ដែលជា អ្នកនិយាយឡើយ ។ ត្រូវតែត្រួតពិនិត្យដោយច្បាស់លាស់ និង ផ្អែកលើភស្តុតាងទាំងអស់ នោះ ពិចារណាតាមទ្រឹស្តី អាចកំណត់បានពីអង្គហេតុ និងឬ ក៏ អាចកំណត់បានពីអត្តសញ្ញាណជនសង្ស័យ ។

ក្រោយពេលដែលប្រមូល និងកំណត់ភស្តុតាងបានហើយយើងត្រូវធ្វើការស្រាវជ្រាវរកភស្តុតាងបន្ថែម។ ដោយភស្តុតាង ដែលស្រាវជ្រាវរកឃើញបាន មួយចំនួនអាច គាំង និង មួយចំនួនអាចច្រានចោលនូវអ្វី ដែលយល់ពីមុនមក បន្ទាប់មកមានធ្វើកោសល្យវិច្ឆ័យលើឯកសារ រកឯកសារ ស្តាប់ចម្លើយសាក្សីពិស្តារ ឬ សាក្សីដែលមិនទាន់បានស្តាប់ចម្លើយ ។

បន្ទាប់ពីឆ្លងកាត់នូវការស្រាវជ្រាវរកបន្ថែមនូវភស្តុតាងមក យើងឈានដល់ ដំណាក់កាលកសាងសំណុំរឿង ដោយដំណាក់កាលនេះ អ្នកស៊ើបអង្កេតត្រូវ តែច្បាស់ក្នុងគំនិត មានរឿងអ្វីកើតឡើង នណាទទួលខុសត្រូវដោយផ្អែកលើភស្តុតាងដែលមាន គួរជំរុំយកទុកចិត្តនិងគួរឱ្យជឿជាក់និងច្បាប់ដែលត្រូវអនុវត្ត។ អ្នកស៊ើបអង្កេត

ត្រូវតែរកឱ្យឃើញចន្លោះប្រហោងនៅក្នុងភស្តុតាងនិងដាក់យុត្តិសាស្ត្រស្វែងរកដើម្បីយកមកបិតនៅកន្លែងខ្វះឱ្យចន្លោះនោះ។ ដំណាក់កាលកសាងសំណុំរឿងភស្តុតាងត្រូវតមានហួសពីវិមតិ សង្ស័យ ។

### ៦.អាជ្ញាធរទទួលបន្ទុកនៃការស៊ើបអង្កេត

ការរកឃើញ និងការត្រួតពិនិត្យបទល្មើសជាតួនាទីរបស់អង្គភាពជំនាញទាំងអស់ដែលមិនស្ថិត ក្នុងអង្គចៅក្រម ប៉ុន្តែស្ថិតក្រោមបញ្ជាអង្គចៅក្រម គឺ នគរបាលយុត្តិធម៌។ ដូចនេះ នគរបាលយុត្តិធម៌ គឺជាសំនុំបុគ្គលិកទាំងអស់ ប៉ុន្តែក៏ជាមុខងារមួយដែលអនុវត្ត ដោយតួអង្គជាច្រើនដែរ។

អ្នកចូលរួមក្នុងការស៊ើបអង្កេតនគរបាលយុត្តិធម៌មានរាយនាមក្នុងមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថានគរបាលយុត្តិធម៌រួមមាន៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- ភ្នាក់ងារសាធារណៈដទៃទៀត ដែលប្រគល់អំណាចដោយច្បាប់ដោយឡែក ដើម្បីធ្វើការត្រួតពិនិត្យបទល្មើសក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

ដើម្បីជាដើមទុនក្នុងការយល់ដឹងបន្ថែមអំពីសមាសភាពរបស់នគរបាលយុត្តិធម៌ក្នុងស៊ើបអង្កេត យើងខ្ញុំនឹងធ្វើការបកស្រាយនៅជំពូកទី២ ដូចតទៅ។

# ជំពូកទី២
# នគរបាលយុត្តិធម៌

# ជំពូកទី២
# នគរបាលយុត្តិធម៌

## ផ្នែកទី១.សមាសភាពមន្ត្រីនគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីការចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ[1] ។ លើសពីនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌[2] ។

នៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺវាមិនស្រួលក្នុងការស្វែងរកភស្តុតាងក៏ដូចជាតាមឱ្យទាន់ហេតុការណ៍ដែលជនបង្ករបានប្រព្រឹត្តនោះទេ ហើយវាមានភាពស្មុគស្មាញក្នុងការកំណត់ថាបទល្មើសមួយដែលបានប្រព្រឹត្តឡើងនោះជាប្រភេទបទល្មើសអ្វី (ឧក្រិដ្ឋ មជ្ឈិម ឬលហុ និងជនណាម្នាក់ ឬក្រុមណាមួយ) ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់យើងបានចែងថានគរបាលយុត្តិធម៌ មានមន្ត្រីនគរបាលយុត្តិធម៌ ៖

នគរបាលយុត្តិធម៌មានសិទ្ធិចាត់ចែងប្រមូលភស្តុតាងទាំងអស់តាមរយៈការចាប់ផ្តើមស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ឬក្នុងករណីបទល្មើសជាក់ស្តែងមានន័យថាករណីដែលអ្នកប្រព្រឹត្តបទល្មើសត្រូវបានចាប់ខ្លួននៅកន្លែងក្នុងករណីមិនជាក់ស្តែង នៅក្រោមអំណាចដឹកនាំរបស់ព្រះរាជអាជ្ញាឬចៅក្រមស៊ើបអង្កេតដូចនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងថានគរបាលយុត្តិធម៌គឺជាជំនួយរបស់តុលាការ និង គន្ថីទី៣ចែងពីការស៊ើបអង្កេត។

ដូចដែលបានរៀបរាប់ខាងលើ ដូច្នេះហើយទើបយើងនិងធ្វើការជជែកវែកញែកអោយបានស៊ីជម្រៅពាក់ព័ន្ធទៅនឹងនគរបាលយុត្តិធម៌នៅក្នុងរឿងក្តីព្រហ្មទណ្ឌនៅក្នុងចំណុចទី២នៃជំពូកទី២ នេះដូចតទៅ។

### កថាខណ្ឌទី១.មន្ត្រីនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ និងមានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងធ្វើការប្រមូលនូវភស្តុតាង ។

មន្ត្រីរាជការចំនួន បី ជំពូកដែលអាចទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិជាអាទិ៍ដូចជា៖

[1]មាត្រា៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នា២០០៧

[2] មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- មន្ត្រីនគរបាល នៃនគរបាលជាតិ
- នាយទាហាន នៃកងរាជអាវុទ្ធហត្ថ និង
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ។

ដើម្បីអាចក្លាយទៅជាមន្ត្រីនគរបាលយុត្តធម៌ គឺត្រូវតែទទួលបាននូវគុណសម្បត្តិតាមរយៈ

## ១.លក្ខខណ្ឌដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌

### ១.១.ការទទួលបានតាមរយៈឋានន្តរស័ក្ត

នៅក្នុងក្របខណ្ឌនគរបាលជាតិ អ្នកដែលមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌គឺ មន្ត្រីនគរបាលជាតិ ដែលមានឋានន្តរស័ក្តចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិច២ឆ្នាំ ក្នុងនគរបាលជាតិ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ។ មន្ត្រីនគរបាល នៃនគរបាលជាតិ ដែលមានសញ្ញាប័ត្រនៃមន្ត្រីនគរបាលតុលាការ មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ។

នៅក្នុងកងរាជអាវុធហត្ថ អ្នកដែលមានឋានៈជានគរបាលយុត្តិធម៌ គឺនាយយទាហាននៃកងរាជអាវុធហត្ថដែលបានបម្រើការងារយ៉ាងតិច២ឆ្នាំក្នុងកងរាជអាវុធហត្ថ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។ នាយទាហានៃកងរាជអាវុធហត្ថដែលមានសញ្ញាប័ត្រនៃមន្ត្រីនគរបាលតុលាការមុនក្រមនីតិវិធីព្រហ្មទណ្ឌនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ។

រដ្ឋមន្ត្រីអាណាព្យាបាលនៃមន្ត្រីនគរបាល ឬ ជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចខាងលើនេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល ឬ នាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយ ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### ១.២.ការទទួលបានតាមរយៈការប្រឡងប្រជែង

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ក្នុង ជំពូកទីពីរ ដំបូងនេះ សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋាន ដូចខាងក្រោម៖

- វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌខ្មែរ
- វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ និង
- វិញ្ញាសារស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងដោយអង្គការសហប្រជាជាតិ។

គណៈមេប្រយោគនៃការប្រឡង ស្ថិតក្រោមអធិបតីភាពរបស់ អគ្គព្រះរាជាអាជ្ញា ឬ ចៅក្រមអយ្យាការអមតុលាការកំពូលដែលទទួលមុខងារនេះ ។

**ក.ទាក់ទងនឹងមន្ត្រីនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅៈ**

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាងពីររូប របស់ក្រសួងមហាផ្ទៃ ។

**ខ. ទាក់ទងនឹងយោធិន នៃកងរាជអាវុទ្ធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅៈ**

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាងពីររូប របស់ក្រសួងការពារជាតិ ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីពាក់ព័ន្ធ ។ សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីសាមី ព្រមទាំងមានការបោះត្រាផងដែរ ។

## ១.៣.ការទទួលបានដោយស្វ័យប្រវត្តិ

អ្នកដែលមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោមត្រូវទទួលដោយស្វ័យប្រវត្តិ នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ៈ

ក.អភិបាល និងអភិបាលរង ខេត្ត ក្រុង អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

ខ.ប្រធាន និងអានុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអង្គស្នងការដ្ឋាននគរបាលជាតិ។

គ . ប្រធាន និងអនុប្រធាននាយដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌និងនាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាសណ្តាប់ធ្នាប់សាធារណៈ ។

ឃ.ប្រធាន និងអនុប្រធាននាយដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ ៖

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន

- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពាបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជាៈ

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការពារអនីតិជន
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ខណ្ឌ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុផ្នែក នគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ។ ប្រធាន និងអានុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ" ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ ប្រធាន និងអនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ. ប្រធាន និងអនុប្រប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"។

ញ. មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ. មេបញ្ជាការនិងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ.មេបញ្ជាការនិងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុកខណ្ឌដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាននិងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកកងរាជអាវុធ ទទួលបន្ទុកកិច្ចការ ព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធាន អង្គភាពផ្នែកផ្សេងទៀតដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្ម ទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីអាណាព្យាបាលនៃមន្ត្រីនគរបាល ឬ ជាអាណាព្យាបាលនៃនាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចខាងលើនេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល ឬ នាយទាហាននៃកកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ជាចុងក្រោយ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថាខ្លួននឹងបំពេញដោយភក្ដីភាពនូវមុខងាររបស់ខ្លួន ហើយសម្បថនេះត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថនេះមិនចាំបាច់ធ្វើជាថ្មីម្ដងទៀតឡើយ នៅពេលដែលបានទទួលនីតិសម្បទានជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## កថាខណ្ឌទី២.សមត្ថកិច្ចដែនដី និងការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តធម៌

### ២.១.សមត្ថកិច្ចដែនដី

មណ្ឌលរដ្ឋបាលដែលបំពេញមុខងារ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗមានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបម្រើការងារ។ ការកំណត់ពីមណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះ មនន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានចាត់តាំងឱ្យទៅបម្រើការងារនៅស្រុកណាមួយនៃខេត្តណាមួយដែលមានសមត្ថកិច្ចដែនដីនៅស្រុកនោះប៉ុណ្ណោះ។

ករណីលើកលែងគឺះ

- នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចលើវិសាលភាពនៃរាជធានីទាំងមូល។
- ការអនុញ្ញាតឱ្យបំពេញប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូលដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ក្នុងករណីបទល្មើសជាក់ស្ដែង។
- ការអនុញ្ញាតឱ្យបំពេញប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ដោយចៅក្រមស៊ើបសួរនៅក្នុងដីការចាត់ឱ្យស៊ើបសួរជំនួស។

ក្នុងករណីដែលមានការពន្លាតដែនដីសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដែនដី។ ចៅក្រមត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។ វិធានសមត្ថកិច្ចខាងដែនដីមានលក្ខណៈដាច់ខាត បើមិនគោរពតាមទេ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ។ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិទទួលបញ្ជា ឬសុំ

បញ្ហាតែពីអាជ្ញាធរតុលាការប៉ុណ្ណោះក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្ម ដូចជា៖

- ទទួលបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ ពិនិត្យនូវបទល្មើសទាំងឡាយ
- ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្ដែង និងបទល្មើសបឋម
- ការអនុវត្តដីការចាប់ឱ្យស៊ើបសួរជំនួស។

## ២.២.សមត្ថកិច្ចសម្ភារៈ

ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធហត្ថក៏ជានគរបាលយុត្តិធម៌ដែរ។ ហេតុនេះ កងរាជអាវុធហត្ថអាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែ ចំពោះ បទល្មើសយោធាមានតែកងរាជអាវុធហត្ថទេដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌។ កិច្ចប្រតិបត្តិការ និង កិច្ចសហប្រតិបត្តិការរវាងនាយកនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ក្នុងពេលបំពេញមុខងារ ជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ។ អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិ អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។

ក្រៅពីនេះ រដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចជានគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ មិនអាចស៊ើបអង្កេតបទល្មើសផ្សេងទៀតបានទេ។

## ២.៣.អំណាចរបស់មន្ត្រីនគរបាលយុត្តធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅតាមក្រមខណ្ឌនៃការស៊ើបអង្កេតថាការ ស៊ើបអង្កេតករណីជាក់ស្ដែង ឬករណីស៊ើបអង្កេតបឋម។

## ២.៤.ការពន្លាតសមត្ថកិច្ចដែនដី

ក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្ដែងតាមអត្ថន័យនៃមាត្រា៨៦(និយមន័យបទឧក្រិដ្ឋឬបទមជ្ឈិម ជាក់ស្ដែង) និងមាត្រា៨៧(ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្ដែង) នៃក្រមនោះហើយប្រសិនបើ មានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពទៅលើ ដែនដីទាំងមូលដោយអនុញ្ញាតឱ្យធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេស នៅក្នុងលិខិតស៊ើប អង្កេត។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងករណី បន្ទាន់ចៅក្រមនេះអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដី គោលការណ៍ ណាធ្វើប្រតិបត្តិការនៅក្រោមមណ្ឌលរបស់ខ្លួននោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចដែនខាងដែនដី។

ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ចត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។[3]

### ២.៥.ផលវិបាកនៃការមិនគោរពវិធានបញ្ញត្តិ

វិធាននៃសមត្ថកិច្ចខាងដែនដីដែលបានអនុម័តនៅក្នុងមាត្រាមុនមុននេះមានលក្ខខណ្ឌដាច់ខាត បើមិនគោរពតាមនោះទេនោះកិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ។[4]

## ផ្នែកទី២. ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌គឺជានាយកនគរបាលស្នងការនិងអធិការនៃនគរបាលជាតិដែលពុំមានសញ្ញាបត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ នាយកកងរាជអាវុធហត្ថដែលពុំមានសញ្ញាបត្រជាន់ខ្ពស់ផ្នែកនគរបាលយុត្តិធម៌និងទាហានដទៃទៀតរបស់កងរាជអាវុធហត្ថ។ ភ្នាក់ងារនីមួយៗត្រូវធ្វើការសម្បថនៅចំពោះមុខសាលាដំបូងថានឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចនេះពិនិត្យបទល្មើស។ អត្ថបទច្បាប់បានបញ្ជាក់យ៉ាងច្បាស់ថាភ្នាក់ងារ យុត្តិធម៌មានអំណាចពិនិត្យបទលហុ។ ភ្នាក់ងារជួយមន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញតួនាទីរបស់ខ្លួនដូចនេះភ្នាក់ងារនគរបាលយុត្តិធម៌គឺជាអង្គការនៃការគ្រប់គ្រងនិងការអនុវត្ត។[5]

### ១.ការទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

ដើម្បីទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌៖

- នាយកនគរបាលនិងនាយនគរបាលរងដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត
- នាយកទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ យោធិផ្សេងទៀតដែលនគរបាលយុត្តិធម៌។

### ២.ការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវសម្បថថាខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួនដោយការធ្វើសម្បថនេះមានដូចជា សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌ និង សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ។

[3] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] សៀវភៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈឆ្នាំ២០០៧

សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន ។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍ ។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទានជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមន្ត្រីក្រសួងយុត្តិធម៌។

សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនឯងដោយស្មោះត្រង់។ សម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមន្ត្រីក្រសួងយុត្តិធម៌។

### ៣.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្ម ដូចតទៅៈ ពិនិត្យបទល្មើសជាអាទិ៍ បទលហុ ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់គេ។ ចំពោះការពិនិត្យបទល្មើសភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ ក្នុងករណីណាក៏ដោយភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើផ្លូវការហាមឃាត់នេះត្រូវទុកជាមោឃៈ។[6]

### ៤.សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីដែលខ្លួនបំពេញមុខងារខ្លួនធម្មតា។នៅពេលដែលជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចក្នុងព្រំដែនដីដែលមន្ត្រីនគរបាលយុត្តិធម៌នោះបំពេញមុខការរបស់ខ្លួន។ ភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចពន្លាតសមត្ថកិច្ចដោយខ្លួនឯងនោះទេប៉ុន្តែខ្លួនអាចអមដំណើរមន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើដំណើរទៅក្រៅដែនដីសមត្ថកិច្ចរបស់ខ្លួនតាមការអនុញ្ញាតឱ្យពន្លាតសមត្ថកិច្ច។

ក្របខណ្ឌស៊ើបអង្កេតការស៊ើបអង្កេត(បទល្មើសជាក់ស្តែងការស៊ើបអង្កេតបឋម) ការអនុវត្តដីកាចាត់ឱ្យសួរជំនួស)មិនមានឥទ្ធិពលលើសមត្ថកិច្ចដែនដីដំបូងរបស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ឡើយ

[6] មាត្រា ៧៦ មាត្រា៧៧ និងមាត្រា៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសមួយចំនួនហើយកាន់តែមានប្រសិទ្ធភាព(ការជួញដូរគ្រឿងញៀន ភេរវកម្មចោរកម្មទ្រង់ទ្រាយធំ ការដោះដូរវត្ថុបុរាណ ការប្រឆាំងប្រយុទ្ធប្រឆាំងនឹងបទល្មើសផ្លូវភេទប្រព្រឹត្តចំពោះកុមារ) ។

អាជ្ញាធរអាចសម្រេចបង្កើតអង្គភាពផ្សេងផ្សេងដែលមានសមត្ថកិច្ចថ្នាក់ជាតិដូចនេះមន្ត្រីនគរបាលយុត្តិធម៌ដែលតែងតាំងក្នុងអង្គភាពនេះអាចធ្វើដំណើរលើដែនដីជាតិទាំងមូល ដោយមិនចាំបាច់សុំការអនុញ្ញាតកម្លាំងសមត្ថកិច្ច។[7]

## ៥.កំហុសដែលត្រូវបានប្រព្រឹត្តនៅពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោក្នុងពេលបំពេញការងាររបស់ខ្លួនត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញាឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ។

# ផ្នែកទី៣.មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន

## ១.ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន

មន្ត្រីរាជការ និងភ្នាក់ងារសារធាណៈ ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើសត្រូវដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។ ចំពោះបែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។ អាស្រ័យហេតុនេះ ដើម្បីផ្តលជាជំនួយក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងចំណុចនេះ ខ្ញុំសូមលើកយកមកបង្ហាញតែច្បាប់ចំនួនពីរតែប៉ុណ្ណោះ ទី១ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងទី២ ច្បាប់ស្តីពីព្រៃឈើ។ ច្បាប់ទាំងពីប្រភេទនេះយើងខ្ញុំនិងធ្វើការបកស្រាយដូចតទៅ៖

ទី១ យោងតាមមាត្រា១០ នៃច្បាប់នេះ មន្ត្រីនៃក្រសួងកិច្ចការនារី បំពេការងារលើវិស័យដែលដែលមានបញ្ញត្តិដោយច្បាប់ខាងលើត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាបណ្តឹងជូសមុខឱ្យជនរងគ្រោះក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាៈធរមាន ។

ទី២ យោងតាមមាត្រា៧៦ និង៧៧ នៃច្បាប់នេះ មន្ត្រីនៃក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ គឺសំដៅទៅលើមន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ មានន័យថា ត្រូវទទួលបាន

[7] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល ឆ្នាំ២០០៩

នីតិសម្បទាន ជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។ មន្ត្រីរដ្ឋបាលព្រៃឈើធ្វើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទានពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

បន្ទាប់ពីមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃផ្សេងទៀត ទទួលបាននូវនីតិសម្បទានពិសេសរួចមកហើយ ពួកគេត្រូវទទួលបានការតែងតាំងជាមុនសិន ។ បុគ្គលដែលមានអំណាចក្នុងការតែងតាំងនេះ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធព្រោះបើផ្អែកលើមាត្រា៨២ នៃក្រមនេះបានចែងថាត្រង់វាក្យខណ្ឌ២បានចែងថាបែបបទនិងនីតិវិធិនៃការផ្តល់នីតិសម្បទានត្រូវកំណត់រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងដែលពាក់ព័ន្ធ ។

**ឧទាហរណ៍៖** បើមន្ត្រីរាជការ និងភ្នាក់ងារសាធារណ៍ដទៃទៀតនោះធ្វើការនៅក្នុងក្រសួងកិច្ចការនារី ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយមន្ត្រីក្រសួសយុត្តិធម៌ ឬក៏ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនេះធ្វើការនៅ ក្រសួង កសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ដូចនេះពួកគាត់ត្រូវបានតែងតាំងដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

## ២.ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ

ការតែងតាំងចំពោះមន្ត្រីរាជការនិង ភ្នាក់ងារសាធារណៈដទៃទៀតបន្ទាប់ពីមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះ ទទួលបាននូវនីតិសម្បទាពិសេសរួចហើយពួកគេត្រូវទទួលបាននូវការតែងតាំងឈ្មោះ៣០ថ្ងៃហើយមានតែមានសំណួរចោទសួរថាតើបុគ្គលប្រភេទណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងពួកគាត់ហើយថាតើមាន សេចក្តីសម្រេចភេទណាតែក្នុងការតែងតាំងពួកគាត់ឆ្លើយតបនឹងសំណួរនេះយើងត្រូវសិក្សាមើលថាតើបុគ្គលដែលមានអំណាចក្នុងការតែងតាំង?

បុគ្គលដែលមានអំណាចក្នុងការតែងតាំងគឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធព្រោះបើផ្អែកតាមមាត្រា៨២ ក្របខ័ណ្ឌនៃក្រុងវ៉ៃជាខណ្ឌពីរបានថាបែបបទនីតិវិធីការផ្តល់នីតិសម្បទានត្រូវកំណត់រវាងមន្ត្រីក្រសួង យុត្តិធម៌និងក្រសួងពាក់ព័ន្ធ

ឧទាហរណ៍បើមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្នុងក្រសួងលើកក្រសួងកិច្ចការនារី ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី។ ចំណែកមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។

- **សេចក្តីសម្រេចក្តីក្នុងការតែងតាំង**

ដូចដែលបានដឹងស្រាប់ហើយថា រដ្ឋមន្ត្រីមានសិទ្ធិចេញសេចក្តីប្រកាសដើម្បីតែងតាំងមន្ត្រីមួយចំនួនដែលនៅក្នុងដែរនៅក្រោមឱវាទរបស់ខ្លួន តែរដ្ឋមន្ត្រីនៃក្រសួងពីផ្សេងផ្សេងគ្នាការតែងតាំងមន្ត្រីតែមួយដូចគ្នាដូចនេះសេចក្តីសម្រេចរួមនោះគេហៅថា **ប្រកាសរួម** ជាក់ស្តែងដើម្បីទទួលនីតិសម្បទានជូនមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌និង រដ្ឋមន្ត្រីនៅក្រសួងចេញប្រកាសរួមដើម្បីទុកជាសេចក្តីសម្រេចក្នុងការតែងតាំងពួកគាត់។

ឧទាហរណ៍ចំពោះមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកិច្ចការនារី មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ពួកគាត់ត្រូវតែតែងតាំងប្រកាសរួមផងដែររវាងមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និង នេសាទ។

## ៣.សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ

សម្បថរបស់មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនៅពេលដែល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ បានចេញសេចក្តីប្រកាសរួមតែងតាំងខ្លួនរួចហើយ មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះ មិនទាន់អាចទៅបំពេញមុខងារនេះបានភ្លាមនោះទេ គឺពួកគាត់ត្រូវឆ្លងកាត់ដំណាក់ចាមួយផ្សេងទៀត ដូចមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ដល់ដំណាក់ការនេះគេឲ្យឈ្មោះថាការធ្វើសម្បថ។

ទីកន្លែងត្រូវធ្វើសម្បថ យោងតាមមាត្រា៨២ត្រង់វក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតអាចមកបំពេញមុខងារបានទាល់តែឆ្លងកាត់នូវដំណាក់កាលសម្បថជាមុនសិន។ ប៉ុន្តែសម្បថរបស់ពួកគាត់មិនធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ ដូចមន្ត្រីនគរបាលយុត្តិធម៌នោះទេ គឺពួកគាត់ធ្វើសម្បថនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ចតាមខេត្តរាជធានីនីមួយៗដូចគ្នានិងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ។ រូបមន្តនៃសម្បថកំណត់ដោយ ប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[8]

នត្ថិភាពនៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតគឺមានភាពខុសគ្នា ត្រូវនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ព្រោះសម្បថរបស់មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតគឺនត្ថិភាព [9]ចំពោះអញ្ញាត្រកម្ម មានន័យថាបើយោងតាមមាត្រាខាងលើគឺមិនមានកំណត់នូវករណីលើកលែងចំពោះសម្បថឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិរួចរាល់នោះចំណុចនេះហើយដែលខ្ញុំមើលឃើញថាភាពខុសគ្នានោះក៏រវាងនគរបាលយុត្តិធម៌ក៏ដូចជាភ្នាក់ងារនគរបាលយុត្តិធម៌ណាព្រោះពួកគាត់មានការលើកលែងមួយចំនួន ចំពោះសម្បថរបស់ខ្លួនដូចបានរៀបរាប់ខាងលើជាដើម ចំពោះសម្បថនេះពុំចាំបាច់ធ្វើឡើងវិញទៀយនៅពេលដែលទទួលបាននីតិសម្បទានជាមន្ត្រីនគរបាលយុត្តិធម៌ឬនៅពេលដែល

[8] សម្បថនេះត្រូវស្បថបំពេញមុខងារដោយស្មោះត្រង់

[9] នត្ថិភាព គឺភាវៈគ្មាន ឬភាពនៃអ្វីៗដែលមិនមាន( យោងតាមសន្ធានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

ទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ពេលក្រោយទៀត។ ផ្ទុយទៅវិញចំពោះមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទាំងនោះពុំមាន ភាពច្បាស់លាស់អំពីចំណុចនេះឡើយ។

## ៤.កំហុសរបស់មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ

ក្រោយពេលទទួលបាននូវប្រកាសរួមតែងតាំងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងអ្នកដឹកនាំមន្ត្រីនៃក្រសួងពាក់ព័ន្ធនិងក្រោយពីបានគេធ្វើសម្បថនៅចំពោះមុខសាលាដំបូងរួចមក មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀត ចំពោះការពិនិត្យលើបទល្មើស មន្ត្រីរាជការនិងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍របាយការណ៍នេះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ។ ប្រសិនបើមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតប្រព្រឹត្តកំហុស ពេលអនុវត្តមុខងាររបស់ខ្លួនតើនឹងមានទណ្ឌកម្មដូចមេចចំពោះគាត់? ហើយដើម្បីដាក់ទណ្ឌកម្មតើគេត្រូវមាននីតិវិធីខាងវិន័យបែបណាខ្លះ?

រាល់កំហុសប្រព្រឹត្តក្នុងពេលដែលអនុវត្តនៅមុខងាររបស់មន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវទទួលដូចជា៖

❖ **នីតិវិធីខាងវិន័យ**

កំហុសត្រូវរាយការណ៍ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយព្រះរាជអារអាជ្ញា ឬចៅក្រមស៊ើបសួរ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ តាមករណីនីមួយៗ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យ។

❖ **ទណ្ឌកម្មខាងវិន័យ**

កាលណាមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី។ ពាក្យសុំដកសិទ្ធិ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា។

❖ **ការហាមឃាត់មិនឱ្យបំពេញមុខងារ**

នៅពេលណាដែលមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងកំហុសនៅពេលបំពេញមុខងារ ដែលឃើញថាមានសភាពធ្ងន់ធ្ងរនៃកំហុសនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម៖

- ហាមមិនឱ្យបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើនបំផុត
- ការហាមមិនឱ្យបំពេញមុខងារជាស្ថាពរ។

❖ **នីតិវិធីនៃកាហាមឃាត់**

មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចពាក្យប្ដឹងតវ៉ាដោយមានសំអាងហេតុ ក្នុងអំឡុងពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចហាមឃាត់នោះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្ដីលើបណ្ដឹងតវ៉ាខាងលើ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ខែ គិតចាប់ពីថ្ងៃទទួលពាក្យប្ដឹង។

# ជំពូកទី៣
# នីតិវិធីនៃការស៊ើបអង្កេត

# ជំពូកទី ៣
# នីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងតំណាក់កាលស៊ើបអង្កេតត្រូវបានគេបែងចែកយ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះយើងឃើញមានការបែងចែកការស៊ើបអង្កេតបទល្មើសជា ២(ពីរ) ដែលរួមមានទី១ គឺការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងទី២ គឺការស៊ើបអង្កេតបទល្មើសមិនជាក់ស្តែង ។ ដោយយោងទៅតាមមាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា អំណាចទាំងឡាយណាដែលមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះ បំពេការងារក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌស៊ើបអង្កេតករណីបឋម ។ ស្ថិតក្នុងករណីនេះដែរ យើងអាចសន្និដ្ឋានបានថាការស៊ើបអង្កេតទាំងពីរ ពិតជាមានភាពខុសគ្នាជាច្រើនផងដែរ ។ ដើម្បីឲ្យកាន់តែច្បាស់ យើងខ្ញុំនឹងធ្វើការបកស្រាយយ៉ាងលម្អិតនៅក្នុងចំណុចនីមួយៗ ។

## ផ្នែកទី១៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌(ករណីបទល្មើសជាក់ស្តែង)

នៅពេលដែលមានបទល្មើសមួយកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវកំណត់ថាអ្វីដែលសំខាន់បំផុតត្រូវកំណត់ថាបទល្មើសនោះជាបទល្មើសជាក់ស្តែង ឬក៏មិនជាក់ស្តែង ។ ពីព្រោះបើយើងពិនិត្យទៅលើ ក្រមនីតិវិធីព្រហ្មទណ្ឌយើងឃើញថា នគរបាលយុត្តិធម៌ទទួលបានអំណាចធំធេងណាស់ ក្នុងការស៊ើបអង្កេតបទល្មើសដូចជា បទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទមជ្ឈិមជាក់ស្តែង ដោយសម្អាងទៅលើភាពបន្ទាន់នៃការធ្វើសកម្មភាព ដើម្បីបញ្ចៀសពីភាពរីករាលដល់សណ្តាប់ធ្នាប់សាធារណៈ និងប្រមូលនៅភស្តុតាងដែលបន្សល់ទុកនៅនឹងកន្លែងប្រព្រឹត្តបទល្មើស ព្រមទាំងដើម្បីធ្វើការខ្លួនចារីសន្មត។ ភាពបន្ទាន់នៅតែមានកាលណាបទល្មើសមួយត្រូវបានប្រព្រឹត្តរួចហើយ តែបានបន្តស្តែងចេញតាមរយៈធាតុសំខាន់ៗដូចជា ការស្រែកដេញចាប់របស់សាធារណៈ ការរកឃើញវត្ថុដែលត្រូវបានលួច ស្លាកស្នាម ឬតម្រុយណាមួយជាដើម ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើនៅកាលៈទេសៈនេះមិនមែនជាបទល្មើសជាក់ស្តែងទេ ហើយគាត់ធ្វើការស៊ើបអង្កេតដោយការប្រើអំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង នោះអ្វីដែលគាត់បានធ្វើទាំងអប្បាទ្ធានត្រូវបានទុកជាអសាបង់ ព្រោះជាកម្មវត្ថុនៃការស្នើសុំមោឃភាព។ ស្ថិតនៅក្នុងស្ថានភាពនេះដែរ យើងនឹងធ្វើការសិក្សាបន្តទៅលើចំណុចនីមួយៗ ថាតើអ្វីទៅជាបទល្មើសជាក់ស្តែង ឬបទល្មើសមិនជាក់ស្តែង ? ហើយមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចអ្វីខ្លះពេលមាននូវបទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែងកើតឡើង ? ក្នុងនេះដែរយើងនឹងធ្វើការរបកស្រាយទៅតាមចំណុចនីមួយៗដូចតទៅ៖

### កថាខណ្ឌទី១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

នៅក្នុងនីតិវិធីនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបា លយុត្តិធម៌ ក្នុងការស៊ើបអង្កេតករណីបទល្មើស ជាក់ស្តែងមានច្រើនបែបដែលយើងនឹងធ្វើការបកស្រាយនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះការស៊ើប អង្កេតបទល្មើសជាក់ស្តែង។ ក៏ប៉ុន្តែមុននឹងជាន់ដល់ការបកស្រាយនូវការស៊ើបអង្កេតករណីបទល្មើសជាក់ ស្តែង ទាល់តែយល់ឱ្យបានស៊ីជម្រៅជាមុនសិនថាតើអ្វីទៅជាបទល្មើសជាក់ស្តែង?

## ១.១.និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨៦ បានចែងយ៉ាងច្បាស់ថាអំពីករណីនៃបទល្មើសជាក់ស្តែងដែលតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបាន ដែលក្នុងមាត្រានោះដែលបានចែងថា បទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺៈ

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម

ត្រូវចាប់ទុកថា ជាបទល្មើសឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក។ ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភឹង ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្នាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីចង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

លើសពីនេះទៅទៀត ក៏មានលក្ខខណ្ឌមួយទៀតត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តធម៌នៅទីនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។[10]

## ១.២. កិច្ចនានានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង

កិច្ចទាំងឡាយណាដែលទាក់ទងនឹងការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះគឺមានចែងក្នុងមាត្រា ៨៥ ដល់មាត្រា ១១០ នៃក្រមនីតិវិធិព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។ នៅក្នុងនោះដែរ បើទោះបីជាការស៊ើបអង្កេតនេះត្រូវធ្វើឡើងក្រោមរូបភាពណាក៏ដោយ ទាំងបទល្មើសជាក់ស្តែង ការស៊ើបអង្កេត ឬដីការចាប់ឱ្យស៊ើបសួរជំនួយ កិច្ចនានាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ គឺមានលក្ខណៈដូចគ្នាទាំងអស់។

[10] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ១.៣. វិធានដំបូងក្នុងការស្រាវជ្រាវនៃបទល្មើស

វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញានេះបើយោងតាម មាត្រា៩៨ ។ ហើយនៅក្នុងវិធានការដំបូងនោះត្រូវតែមានដូចជា៖

- មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនទៅព្រះរាជអាជ្ញា
- មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅទីកន្លែងដែលកើតហេតុ ដើម្បីពិនិត្យបទល្មើស
- មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធានារ៉ាបរងរក្សាទុកដម្រុយភស្តុតាងនៃបទល្មើស
- មន្ត្រីនគរបាលយុត្តិធម៌ត្រូវហាមមិនឱបុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងងបទល្មើសរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ក្នុងករណីបន្ទាន់ ដោយគោរពតាមលក្ខខណ្ឌដូចជា៖

- ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតត្រូវចុះនិទ្ទេស នៅក្នុងលិខិតស៊ើបអង្កេត
- មន្ត្រីនគរបាលយុត្តិធម៌ ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដែនដី ដែលប្រតិបត្តិការក្រោមណ្ឌលរបស់ខ្លួន
- ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដី។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។[11]

### ១.៤. ការឆែកឆេរ

ការឆែកឆេរ ត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងតឹងរឹងបំផុត ហើយនៅក្នុងមាត្រានេះបញ្ជាក់ជូនមន្ត្រីនគរបាលយុត្តិធម៌ អាចមានសិទ្ធិក្នុងការឆែកឆេរបាន។ នៅក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលចុះប្រតិបត្តិការ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

[11] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដោយយោងតាមគោលការណ៍ដែលមានចែងនេះ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរ មុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ឡើយ លើកលែងតែមានដូចជា ៖

- ករណីជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង
- ករណីដែលជាការចាប់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង
- ករណីមានសម្រែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង
- ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើចំហដល់សាធារណៈជន សំដៅទៅដល់ទីតាំងដែលបើអាជីវកម្ម នៅពេលយប់ ខុសពីម៉ោងធែលឆេរ ដូច្នេះអាចធ្វើការឆែកឆេរបាននៅទីកន្លែងដោយមិនគោរពតាមលក្ខខ័ណ្ឌពេលវាលានៃការឆែកឆេរបាន។
- ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

រាល់ប្រតិបត្តិការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលក្នុងនោះមាន៖

- អនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោង នៃការអនុញ្ញាតនោះ។
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

ដោយឡែក មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ ដោយមានវិជ្ជាជីវៈមួយចំនួនដែលត្រូវបានគាំពារជាពិសេសដោយច្បាប់ ។ ផ្លូវច្បាប់គាំពារវិជ្ជាជីវៈ ទាំងក្នុងក្របខ័ណ្ឌនីតិវិធីព្រហ្មទណ្ឌដោយបានហាមឃាត់មិនឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបាឡើយ។ ដូច្នេះការឆែកឆេរត្រូវគោរពនូវលក្ខខណ្ឌពិសេសនេះក្នុងនោះសំដៅដល់វិជ្ជាជីវៈចំនួន ២ គឺ ″ **វិជ្ជាជីវៈមេធាវី និងវិជ្ជាជីវៈសារព័ត៌មាន** ។ ការឆែកឆេរនេះមានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រត្តិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសម៊ី។ ម្យ៉ាងវិញទៀត ការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាស នៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍របស់មន្ត្រីនគរបាលយុត្តិធម៌បានចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះមិនត្រឹមត្រូវ ។

## ១.៥.ការបិទស្លាកបោះត្រាលើវត្ថុតាងដែលចាប់យក

នៅក្នុងក្របខណ្ឌនៃការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ប្រសិនបើរកឃើញនូវវត្ថុតាងណាមួយដែលគួរឱ្យសង្ស័យ ដោយពួកគាត់មានអំណាចក្នុងការចាប់យកវត្ថុតាងនោះបាន ។ ក្រោយពេលដែលចាប់យកវត្ថុតាងនោះមកហើយ ចាំបាច់ត្រូវតែវេចខ្ចប់នូវវត្ថុតាងនោះទុក។ នៅ

ពេលដែលចាប់យកនៅវត្ថុតាងនោះ គាត់ត្រូវបង្ហាញវត្ថុដែលចាប់បាននោះដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច ត្រូវយកទៅវេចខ្ចប់ ដោយពេលដែលវិចខ្ចប់ត្រូវបិទស្លាក និងបោះត្រា ដើម្បីរក្សាធានាមិនឱ្យមានការលួចដូរបានឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យកដែលពិពណ៌នាពីវត្ថុតាង និងទីកន្លែងដែលរកវាឃើញ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីនាក់។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវភ្ជាប់ជាមួយនូវកំណត់ហេតុនៃការឆែកឆេរ ដែលបញ្ជាក់ឱ្យបានច្បាស់អំពីការអនុញ្ញាតនៅពេលវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់បានផ្តល់ឱ្យ ដែលអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

## ១.៦.ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើ ត្រូវធ្វើការពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចមានចែងនៅមាត្រា ១៦៣ នោះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ១.៧.កំណត់ហេតុស្តីពីការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ដោយមន្ត្រីនគរបាលយុត្តិធម៌ អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស។

ដោយការស្តាប់ចម្លើយនីមួយៗ ត្រូវតែមានធ្វើកំណត់ហេតុដូចតទៅៈ

- កំណត់ហេតុនីមួយៗ ត្រូវដកស្រង់តាមសេចក្តីត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ
- មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការស្តាប់ចម្លើយជនទាំងនោះ ដោយត្រូវមានកំណត់ហេតុ
- ក្នុងករណីដែលចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដោយមានសម្បថថានិយាយការពិត ស្របតាមជំនឿ និងសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជា នគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធក្នុងរឿងជាមួយគ្នាបានទេ
- ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ
- មុននិងចុះហត្ថលេខា ឬ ផ្តិតម្រាមដៃបុគ្គលនោះត្រូវស្តាប់ ឬអានកំណត់ហេតុឡើងវិញ
- កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

## ១.៨.ការបញ្ជាឱ្យចូលខ្លួនក្នុងករណីបទល្មើសជាក់ស្តែង

គ្រប់ការស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិកោះហៅ ជនដែលមានផលប្រយោជន៍ ដើម្បីមកបំភ្លឺ ឬ ផ្តល់ព័តមាន ។ ក្នុងករណីជននេះរឹងទទឹងដោយមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើរសុំទៅព្រះរាជអាជ្ញា ដើម្បីសុំឱ្យចេញបញ្ជាឱ្យចូលខ្លួន ព្រោះបញ្ជាឱ្យចូលខ្លួននេះមកបំភ្លឺ ឬក៏ផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ ឬកងកម្លាំងសាធារណៈដែលចាំបាច់ចាប់ខ្លួនជននេះមកបំភ្លឺមុខមន្ត្រីនគរបាលយុត្តិធម៌។ ការបញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានការបោះត្រាផងដែល។ ដូចនេះ កិច្ចទាំងឡាយណាដែលមិនគោរពនូវវិធានដូចដែលបានកំណត់នៅក្នុងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះនឹងនាំឱ្យមានមោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធម៌ក្នុងការស្តាប់ចម្លើយ។[12]

### ១.៩.ការឃាត់ខ្លួន

ដោយយើងពិនិត្យឃើញថា ការឃាត់ខ្លួនក្នុងការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែងមានចែងពីមាត្រា ៩៦ ដល់មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។ ថាតើការឃាត់ខ្លួនជនណាម្នាក់ត្រូវប្រើនីតិវិធីអ្វីខ្លះក្នុងការដោះស្រាយ ? ហើយត្រូវគោរពនូវបទដ្ឋានគតិយុត្តិអ្វីខ្លះក្នុងការឃាត់ខ្លួនជនណាម្នាក់ ? នៅក្នុងនេះផងដែល យើងខ្ញុំនឹងលើកយកមកបកស្រាយទៅតាមចំណុចនីមួយៗដូចតទៅៈ

#### ១.៩.១.បែបបទនៃការឃាត់ខ្លួន

ក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើលក្ខខ័ណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា

នៅពេលមានការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។[13] ការឃាត់ខ្លួនក្នុងករណីស៊ើបអង្កេតបឋម ក៏

[12] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[13] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដូចក្នុងករណីជាក់ស្តែង នៅពេលដែលមានតម្រុយពីអំពើបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ ឬត្រូវអនុវត្តវិធានការបង្ខំណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញា ព្រមទាំងបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានឃាត់ខ្លួនជាមុនមានន័យថា៖

ប្រសិនបើក្រោយពីការស៊ើបអង្កេត ពិនិត្យឃើញច្បាស់ថា ពិតជាមានបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ ហើយមានមូលហេតុចាំបាច់តម្រូវឱ្យឃាត់ខ្លួនមិនបាន មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំឃាត់ខ្លួនជនសង្ស័យទៅព្រះរាជអាជ្ញា។ ការស្នើសុំឃាត់ខ្លួនព្រះរាជអាជ្ញាទាំងពីរយ៉ាងនេះ គឺជាការផ្តើមគំនិតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែភ្ជាប់ទៅជាមួយនូវវត្ថុតាងដែលតម្រូវឱ្យមានការឃាត់ខ្លួនជាចាំបាច់នោះ ក្នុងការទទួលខុសត្រូវលើសំណើខ្លួនហើយលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ទើបអាចធ្វើការឃាត់ខ្លួនបាន។

## ១.៩.២.រយៈពេលនៃការឃាត់ខ្លួន

រយៈពេលនៃការឃាត់ខ្លួនជនណាម្នាក់ ត្រូវមានរយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ទោះបីមួយណាក៏ដោយ ។ ចំពោះបទល្មើសឧក្រិដ្ឋនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបាន តែត្រូវស្នើរសុំទៅព្រះរាជអាជ្ញា។ ការឃាត់ខ្លួនអាចពន្យាពេលបាន មិនអាចឱ្យលើសពី ២៤ ម៉ោងឡើយ ដោយមិនគិតពីថេរវេលាចាំបាច់ដឹកជញ្ជូន។ ជាទូទៅនៅពេលដែលមានការស្នើសុំ ព្រះរាជអាជ្ញានឹងធ្វើការផ្ទៀងផ្ទាត់ថា ការស្នើសុំមានមូលហេតុត្រឹមត្រូវសមហេតុផលដែរឬទេ? ដោយមិនមែនជាការស្នើសុំពន្យាក្នុងគោលដៅទុច្ចរិត ចង់បំបិទសិទ្ធិសេរីភាពរបស់គេ ចង់ឱ្យគេភ័យខ្លាចដើម្បីឱ្យគេសារភាព ពោលគឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតម្រុយច្បាស់លាស់ថា បុគ្គលនោះមានពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសដែរ ទើបអាចសុំពន្យាពេលឃាត់ខ្លួនក្នុងគោលដៅយកចម្លើយបន្ថែមទៀតឬ ភស្តុតាង ផ្សេងបន្ថែមទៀតរបស់ខ្លួន។ ដូចនេះយើងពិនិត្យឃើញថា ការពន្យាពេលនៃការឃាត់ខ្លួនគឺត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដូចជា៖

- មានតម្រុយបង្ហាញឱ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនជានីតិជន ក្នុងបទឧក្រិដ្ឋ
- ការពន្យាពេលជាវិធានការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ
- ការអនុសញ្ញាតពន្យាពេលនៃការឃាត់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

បន្ទាប់ពីផុតរយៈពេលនៃការឃាត់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការដោះលែងបុគ្គលនោះ ប្រសិនបើបុគ្គលនោះមិនមានការអនុញ្ញាតត្រឹមត្រូវណាមួយពីអាជ្ញាធរតុលាការក្នុងការឃុំខ្លួនបន្តទៀតនោះ។ ក្នុងករណីបទមជ្ឈិមនៅពេលដែលភស្តុតាងបញ្ជាក់ថា ជនជាប់ចោទយ៉ាំងយ៉ាំងជាពិរុទ្ធនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស្នើសុំពន្យាពេលឃាត់ខ្លួនបើវិធានការនេះចាំបាច់ដើម្បី ការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាពេលដែលមានការស្នើសុំ ពីព្រះរាជអាជ្ញានឹងធ្វើការផ្ទៀងផ្ទាត់មើល លើការពន្យាពេលនៃការឃាត់ខ្លួននោះ។ រាល់ការ

អនុសញ្ញាតពន្យាពេលនៃការឃាត់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូននៅក្នុងសំណុំរឿង ។

### ១.៩.៣.ការឃាត់ខ្លួនចំពោះអនីតិជន

ដូចដែលយើងបានសិក្សារួចមកហើយនៅចំណុចខាងលើដែលនិយាយទាក់ទងទៅនឹងការឃាត់ខ្លួនរបស់នីតិជន ។ ដោយឡែកនៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាបន្ថែមទៅលើការឃាត់ខ្លួនអនីតិជនវិញម្តង។ ដើម្បីឱ្យកាន់តែច្បាស់នូវការឃាត់ខ្លួន ក៏ដូចជារយៈពេលនៃការឃាត់ខ្លួន ការពន្យាពេលនៃការឃាត់ខ្លួននោះ យើងនឹងធ្វើការបកស្រាយដូចតទៅៈ

ក្នុងករណីជនជាប់ឃុំជាអនីតិជន ការឃាត់ខ្លួនអនីតិជនអាចធ្វើបានចំពោះតែអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងប៉ុណ្ណោះ។ ការពន្យាពេលមិនអាចបានទេ ប្រសិនបើបុគ្គលឃាត់ខ្លួននោះជាអនីតិជន។ ជាទូទៅ អនីតិជនមិនអាចត្រូវបានឃាត់ខ្លួនរយៈពេលយូរដូចនីតិជនទេ។ រយៈពេលនៃការឃាត់ខ្លួន ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដូចជាៈ

**ចំពោះបទឧក្រិដ្ឋ**

- អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ : មិនអាចត្រូវគេឃាត់ខ្លួនហួសពី ៣៦ ម៉ោង ។
- អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ : មិនអាចត្រូវគេឃាត់ខ្លួនហួសពី ៤៨ ម៉ោង ។

**ចំពោះបទមជ្ឈិម**

- អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ : មិនអាចត្រូវគេឃាត់ខ្លួនហួសពី ២៤ម៉ោង ។
- អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ : មិនអាចត្រូវគេឃាត់ខ្លួនហួសពី ៣៦ម៉ោង ។
- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំពុំអាចត្រូវបានគេឃាត់ខ្លួនបានឡើយ។

នៅក្នុងចំណុចនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំពោះការឃាត់ខ្លួនអនីតិជននោះ គឺកាលណាបុគ្គលដែលត្រូវបានគេឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ឃាត់ខ្លួនអនីតិជន ត្រូវរកគ្រប់មធ្យោបាយជូនព័ត៌មានអំពីការឃាត់ខ្លួនឱ្យបានដល់ឪពុក ម្តាយ ឬអ្នកដំណាងដែលទទួលខុសត្រូវលើអនីតិជននេះជាបន្ទាន់។[14]

### ១.៩.៤.សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន

- **សិទ្ធិប្រាស្រ័យមេធាវីក្នុងពេលឃាត់ខ្លួន**

ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន ក្នុងរយៈពេល ២៤ម៉ោងកន្លងផុត បុគ្គលដែល(ផ្តើមឃាត់ខ្លួន) ឃាត់ខ្លួន អាចសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលបានជ្រើសរើស ហើយត្រូវប្រាកដថាជននេះ

[14] មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដែលមិនពាក់ព័ន្ធបទល្មើសក្នុងរឿងជាមួយគ្នានេះទេ ។ជននេះក៏ត្រូវបានទទួលដំណឹងពីការស្នើសុំ ឬការជ្រើសរើសនេះផងដែល តាមរយៈគ្រប់មធ្យោយបាយ និងជាបន្ទាន់ផងដែរ ។ ជននេះមានរយៈពេល ៣០ នាទី ហើយក្នុងលក្ខខ័ណ្ឌ ធានាការសម្ងាត់នៃការសន្ទនានេះ ។ ការសន្ទនាជននេះ អាចធ្វើជាកំណត់សម្គាល់ជាលាយលក្ខអក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿងផងដែរ។[15]

❖ **សិទ្ធិទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួន**

ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួនត្រូវធ្វើឡើងដូចតទៅៈ

- ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឲ្យគ្រូពេទ្យមកពិនិត្យជនត្រូវឃាត់ខ្លួនបានគ្រប់ពេលវេលា រាល់ការពិនិត្យត្រូវចេញសេចក្តីបញ្ជាក់សុខភាព
- គ្រូពេទ្យត្រូវពិនិត្យមើលថា តើសុខភាពជនត្រូវឃាត់ខ្លួននោះ សមស្របនិងការឃាត់ខ្លួនដែរឬទេ។
- ប្រសិនបើសុខភាពបុគ្គលនោះមិនសមស្របនិងការឃាត់ខ្លួនទេត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា
- គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។
- មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការចុះពិនិត្យសុខភាព

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន។[16]

## ១.៩.៥.បញ្ជីនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងកន្លែងនីមួយៗ តាមអង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីស្តីពីការឃាត់ខ្លួនជាចាំបាច់ ហើយចុះឱ្យបានត្រឹមត្រូវ គ្រប់ការឃាត់ខ្លួនត្រូវមានចុះក្នុងបញ្ជីដោយមានសេចក្តីដូចតទៅនេះ៖

១. ឈ្មោះនិងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន

២. ចុះអត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

៣. ថ្ងៃខែឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

៤. ឈ្មោះនិងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួនដោយថាហេតុ

[15] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[16] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

៥. ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលរបស់ខ្លួនជាយថាហេតុ

៦. ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

បញ្ជីនេះក៏ត្រូវកាន់កាប់ជាប្រចាំសម្រាប់ទុកជូនអាជ្ញាធរតុលាការពិនិត្យគ្រប់ពេល។

### ១.៩.៦.កំណត់ហេតុសរុបនៃការឃាត់ខ្លួន

កំណត់ហេតុសរុបនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាកំណត់ហេតុចុងក្រោយបង្អស់នៃការឃាត់ខ្លួន។ កំណត់ហេតុនេះ គឺជាការកត់ត្រាហេតុការណ៍ទាំងអស់ក្នុងអំឡុងពេលឃាត់ខ្លួនជនណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងពីការឃាត់ខ្លួនដល់ជននោះ ដោយប្រាប់ឱ្យបានដឹងពីមូលហេតុនូវសេចក្ដីសម្រេចចិត្តឃាត់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់សាមីជនខ្លួនឱ្យបានដឹងផងពីសិទ្ធិជំនួយផ្នែកច្បាប់ដែលមានចែងក្នុងមាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះបុគ្គលដែលត្រូវបានឃាត់ខ្លួនណាដែលមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែឱ្យបុគ្គលនោះ។ គ្រប់ការឃាត់ខ្លួន ត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួននេះ ដោយត្រូវមានចុះនិទ្ទេសដូចតទៅៈ

- ឈ្មោះនិងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន
- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០
- ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨
- ឈ្មោះនិងឋានៈរបស់ចៅក្រមដែលជាថាហេតុ បានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន
- ថេរវេលាការស្ដាប់ចម្លើយនីមួយៗ និងការសំរាកដែលនៅចំពោះការស្ដាប់ចម្លើយ៍នីមួយៗ
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។[17]

[17] មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។ កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង។ កំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនដែលបានឃាត់ខ្លួនក្រោយសាមីខ្លួនបានអានរួចសាមី)ខ្លួនចេះអក្សរឬមន្រ្តីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ឬប្រើអ្នកបក ( ប្រែ ដោយហេតុសាមីខ្លួនមិនចេះអានភាសាខ្មែរ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្ដិតម្រាមដៃ មន្រ្តីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។

### ១.១០.ការបញ្ជូនខ្លួន

ដូចជាយើងបានសិក្សារួចមកហើយនៅចំណុចរយៈពេលនៃការឃាត់ខ្លួន អាចឈាន់ដល់ ៤៨ម៉ោងនេះ ដោយយោងទៅតាមច្បាប់ដែលបានកំណត់ ។ ដែលច្បាប់អនុញ្ញាតជាអតិប្បរមាគឺ ៤៨ម៉ោង ហើយចំពោះបទឧក្រិដ្ឋដែលឃើញមានតម្រុយអាចពន្យាពេលបាន ២៤ម៉ោង បន្ថែមទៀតនេះគ្រាន់តែជារយៈអតិប្បរមា មិនមែនមានន័យថា ទាល់តែគ្រប់ ៤៨ម៉ោងទើបអាចបញ្ជូនខ្លួនជននោះបានទេ។ ការបញ្ជូបខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួននៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ បញ្ជូនខ្លួនទៅព្រះរាជអាជ្ញាតែម្តង។ ពាក់ព័ន្ធទៅនឹងការបញ្ជូនខ្លួននេះដែល គឺយើងត្រូវសិក្សាទៅលើ ២ ចំណុចបន្ថែមដូចខាងក្រោមៈ

### ១.១០.១ការបញ្ជូនខ្លួនបុគ្គលដែលបានឃាត់ខ្លួន

នៅពេលដែលផុតកំណត់រយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលបានឃាត់ខ្លួននេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា។ ក្នុងករណីព្រះរាជអាជ្ញា ពិនិត្យទៅមិនឃើញថាមិនមានអ្វីធ្ងន់ធ្ងរនោះទេ គាត់អាចនឹងមិនបញ្ជូនជននោះទៅចៅក្រមស៊ើបសួរបន្តនោះទេ ដោយគាត់នឹងធ្វើតាមនីតិវិធីរបស់គាត់ ឬត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ ។ ដោយសេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនខ្លួនទៅចៅក្រមស៊ើបសួរ ឬត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ ។[18]

### ១.១០.២.រយៈពេលនៃការបញ្ជូនខ្លួន

បុគ្គលដែលបានឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។ ប្រសិនបើការបង្ហាញខ្លួនរបស់ជនដែលត្រូវបានឃាត់ខ្លួន មិនអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹងជញ្ជូន ឬចម្ងាយផ្លូវនៃការដឹងជញ្ជូននោះ ត្រូវការរយៈពេលបន្ថែមដែលអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។

[18] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៅក្នុងករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានគេឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ មូលហេតុនៃការឃើតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។[19]

## កថាខណ្ឌទី១៖ វិធានទាក់ទងនឹងការស៊ើបអង្កេតជាក់ស្តែង

ទាក់ទងទៅនឹងវិធាននេះផងដែល យើងនឹងបង្ហាញពីវិធានមួយចំនួនសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ដែលទាក់ទងទៅនឹងករណីស៊ើបអង្កេតជាក់ស្តែង ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ត្រង់មាត្រា ១០៥ ដែលបានហាមមិនឱ្យមន្ត្រីនគរបាលយុត្តិធម៌មានអំណាចស្តាប់ចម្លើយ និងថតសម្លេងនៃការសន្ទនាតាមប្រព័ន្ធទូរស័ព្ទបានឡើយ។

### ១.១.ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង ត្រូវបានកំណត់ដូចតទៅ ថិរវេលាមិនអាចលើសពី ៧ ថ្ងៃ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចនៃការស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ ប្រសិនបើ មិនបានបញ្ចប់ក្នុងរយៈពេល ៧ ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា។

### ១.២.ការហាមឃាត់មិនឱ្យស្តាប់ចម្លើយឯកឯង

នៅត្រង់ចំណុចមួយដែលមានចែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ ត្រង់មាត្រា ១០៥ ជំពូកទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅក្នុងនោះដែលបានហាមមិនឱ្យមន្ត្រីនគរបាលយុត្តិធម៌មានអំណាចស្តាប់ចម្លើយនិងថតសម្លេងនៃការសន្ទនាតាមប្រព័ន្ធទូរស័ព្ទបានឡើយ ហើយរឹតតែមិនអាចឱ្យ មន្ត្រីនគរបាយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ខ្លួន និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ សារតាមទូសារ ឬ សារតាមអិនធើណែតបាននោះដែរ ។

### ១.៣.ការបញ្ជូនកំណត់ហេតុ វត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ កាលណាបុគ្គលណាមួយត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូននោះផងដែរ ។ ចំពោះករណីកំណត់ហេតុដែលត្រូវធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌នោះត្រូវចុះនិទ្ទេសដូចជា៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

[19] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌
- កាលបរិច្ឆេទ ។

នៅទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅត្រឹមទំព័រ ។ កំណត់ហេតុត្រូវស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួនត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។[20]

ឧទាហរណ៍៖ ដោយមានការយល់ព្រមលុបឈ្មោះ **ខ** ដោយធ្វើការកែរដាក់ **ឃ** វិញនិងមានចុះហត្ថលេខា។

តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់**ឯកសារដើម** មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតទាល់តែមានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។ ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។[21]

## ១.៤.មោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិ

ចំពោះកិច្ចទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីរាជការនឹងភ្នាក់ងារសាធារណៈដោយមិនគោរពវិធាន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវទុកជាមោឃភាព ។

មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ ក្នុងករណីស៊ើបអង្កេតជាក់ស្តែង និងទម្រង់ការដូចមានចែងក្នុង ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និង ការពិនិត្យ)
- មាត្រា ៩១ (ការឆែកឆេរ)
- មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)
- មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)
- មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ)
- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

[20] មាត្រា ១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[21] មាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- មាត្រា ៩៨ (ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន)
- មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមមិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ)

## កថាខណ្ឌទី២៖ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង

ទាក់ទងនឹងការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងបទល្មើសជាក់ស្តែងពួកគាត់ក៏អាចធ្វើការស៊ើបអង្កេតនៅក្នុងករណីបទល្មើសមិនជាក់ស្តែងបានដែល ។ បទល្មើសមិនជាក់ស្តែង គឺជាបទល្មើលមួយដែលស្ថិតនៅក្នុងករណីនៃការស៊ើបអង្កេតបឋម ឬ ការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តន៍ទៅតាមមាត្រា ១១១ ដល់មាត្រា ១១៨ នៃក្រមនីតិវិធិព្រហ្មទណ្ឌ។ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតនៅក្នុងករណីបទល្មើសមិនជាក់ស្តែងបានដោយគ្រាន់តែគោរព នូវនីតិវិធីមួយចំនួនដូចតទៅ៖

### ២.១.ការបើកការស៊ើបអង្កេតបឋម

នៅក្នុងករណីនៃការបើកការស៊ើបអង្កេតបឋម មានភាពខុសគ្នាទៅនឹងការបើកការស៊ើបអង្កេតករណីជាក់ស្តែងដូចដែលមានចែងក្នុងមាត្រា ១១១ បានចែងថា ( កាលណាបានដឹងពីអំពើដែលអាចជា បទឧក្រិដ្ឋ ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា)។ គួរបញ្ជាក់ផងដែលថា ក្នុងការអនុវត្តន៍ជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌ ចំពោះការបើកការស៊ើបអង្កេតបឋម ត្រូវធ្វើការស្នើសុំបើកការស៊ើបអង្កេតបឋម ពីព្រះរាជាអាជ្ញាជាមុនសិន ដើម្បីបន្តការអនុវត្តទៅតាមនីតិវិធី ។

នៅក្នុងករណីព្រះរាជអាជ្ញាអនុញ្ញាត គាត់ត្រូវចុះនិទ្ទេសថា អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតបឋមតាមការស្នើសុំ ដោយអនុវត្តតាមមាត្រា ៣៧ ៧៤ និង១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្រោយពីបានការអនុញ្ញាត ក្នុងការបើកការស៊ើបអង្កេតបឋមតាមការស្នើសុំហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាត់ការទៅតាមនីតិវិធីភ្លាម ដោយធ្វើការកោះហៅជនដែលសង្ស័យ ឬ បុគ្គលដែលសង្ស័យថាប្រព្រឹត្តបទល្មើស ឱ្យចូលមកកាន់ការិយាល័យជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌ដើម្បីសាក់សួរអំពីរឿងហេតុ ។ ក្នុងករណីដែលកោះហៅនេះជនដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសមិនព្រមចូលមកបំភ្លឺ អំពីរឿងហេតុនោះទេ មន្ត្រីនគរបាលយុត្តិធម៌ និងធ្វើទៅតាមនីតិវិធី គឺធ្វើសំណើរសុំដីកាបញ្ជាឱ្យចូលខ្លួនមកបំភ្លើ អំពីរឿងហេតុនោះ។

### ២.២.វិធានទាក់ទងនឹងការស៊ើបអង្កេតបឋម

នៅក្នុងនេះផងដែលវិធានដែលត្រូវអនុវត្ត នៅក្នុងករណីស៊ើបអង្កេតបឋម យើងសង្កេតឃើញថាមិនសូវជាមានភាពខុសគ្នាប៉ុន្មានទេ ទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែងព្រោះមានមាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ថាបទបញ្ញត្តិនៃមាត្រាចំនួន ដែលមានចែងនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែងត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋមដែរ ។ បទបញ្ញត្តទាំងនេះរួមមានៈ

- មាត្រា ៩០ ( កំណត់ហេតុលើកការស្រាវជ្រាវ និងការពិនិត្យ )
- មាត្រា ៩៥ ( ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ )
- មាត្រា ១០៥ ( ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍ )
- មាត្រា ១០៧ ( ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា )
- មាត្រា ១០៨ ( និទ្ទេសដែលត្រូវចុះនៅក្នុងតំណត់ហេតុ )

នៃក្រមនេះ ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋម។

ដូចជាយើងបានអាននៅចំណុចខាងលើហើយថាចំណុចទាំង ៥ នេះ រួចមកហើយដោយសារតែវិធានទាំងអស់នេះ យើងធ្វើការបកស្រាយយ៉ាងលម្អិតរួចមកហើយនៅក្នុងករណីនៃការស៊ើបអង្កេតជាក់ស្តែង ។

### ២.៣.មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

ចំពោះវិធាន និងទម្រង់ការដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនាំឱ្យមានមោឃភាពនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបអង្កេតបឋម មោឃភាពនៃនីតិវិធី ដែលរួមមានដូចជា ៖

- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមមិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១១៣ (ការឆែកឆេរ)
- មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួនការស៊ើបអង្កេតបឋម)

កិច្ចទាំងឡាយណាដែលមានលក្ខណៈដាច់ខាត់ត្រូវតែគោរពតាម បើពុំដូច្នេះទេនាំឱ្យមានមោឃភាពនៃនីតិវិធី។

### ២.៤.ការឆែកឆេរ

ការឆែកឆេរនៅក្នុងការស៊ើបអង្កេតបឋម ( បទល្មើសមិនជាក់ស្តែង ) មន្ត្រីនគរបាលយុត្តិធម៌អាចចុះឆែកឆេរបានដោយត្រូវគោរពនូវចំណុចមួយចំនួនដូចតទៅៈ

១.អាចសុំម្ចាស់ទីកន្លែងចូលឆែកឆេរ និងចាប់យកវត្ថុតាងមកពិនិត្យបានដោយពុំទាន់ចាំសុំយោបល់ពី . ព្រះរាជអាជ្ញា ប្រសិនបើម្ចាស់ទីកន្លែងនោះយល់ព្រមអនុញ្ញាឱ្យប៉ុន្តែការអនុញ្ញាតត្រូវតែមានជាលាយលក្ខណ៍អក្សរដោយស្មោះត្រង់ គ្មានការគៀបសង្កត់ណាមួយជាដាច់ខាត។

២.ប្រសិនបើអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញារួច ព្រះរាជអាជ្ញាសុំទៅប្រធានសាលាដំបូង ហើយលុះត្រាតែប្រធានសាលាដំបូងចេញដីកាឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា ទើបព្រះរាជអាជ្ញាត្រូវដឹកនាំឆែកឆេរផ្ទាល់បាន។

៣.ក្នុងការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី០២នាក់ហើយសាក្សីអាចត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ក្រៅពីនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួម។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង ០៦ព្រឹក និងក្រោយម៉ោង ០៦ល្ងាចឡើយ ប៉ុន្តែបើកិច្ចការបន្តគឺអាចបន្តបានតាមពេលសមរម្យ។ ការឆែកឆេរត្រូវតែធ្វើកំណត់ហេតុ និងអនុវត្តតាមខ្លឹមសារ មាត្រា ៩១ ជាដាច់ខាត។

៤.កាលណាការស៊ើបអង្កេតជាបឋមនោះទាក់ទងនឹងបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង តែត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។ កាយល់ព្រមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឲ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវដឹកនាំការឆែកឆេរដោយផ្ទាល់ និងគោរពតាមនីតិវិធី ដែលមានចែងក្នុងមាត្រា ១១៣ នេះ។

## ២.៥.ការបញ្ជាឱ្យចូលខ្លួន

ការបញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបឋម ត្រូវយកមកអនុវត្តដូចគ្នានឹងបទបញ្ជាឱ្យចូលខ្លួនក្នុងករណីនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងដូចគ្នាដែរ ។ ក្នុងនេះផងដែរមន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅនិងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មាននៃរឿងហេតុ ។ បុគ្គលដែលបានកោះហៅត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមិនព្រមចូលខ្លួនតាមការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌ នោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាភ្លាមដើម្បីសុំដីកាបញ្ជាឱ្យចូលខ្លួន ។ ដីកាបញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះ អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា។ ការអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំង

សាធារណៈ ដើម្បីបង្ខំឱ្យបុគ្គលនោះចូលបង្ហាញខ្លួន ។ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបន្តនីតិវិធីស្តាប់ចម្លើយ បុគ្គលដែលបានសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ។

### ២.៦.ការឃាត់ខ្លួនជនសង្ស័យ

អត្ថន័យនៃខ្លឹមសារក្នុងការឃាត់ខ្លួនជនជាប់សង្ស័យក្នុងករណីបទល្មើសមិនជាក់ស្តែង គឺយើងឃើញថា មានលក្ខណៈដូចគ្នានឹងការឃាត់ខ្លួនក្នុងករណីបទល្មើសជាក់ស្តែងដែរ ។ កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទក្រិដ្ឋ ឬបទមជ្ឈិមនោះ បទបញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួន នៃមាតិកាទី២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគន្តីនេះ ត្រូវយកមកអនុវត្ត ។

### ២.៧.កំណត់ហេតុស្តីពីការស្រង់ចម្លើយ

ការស្តាប់នៅចម្លើយនីមួយៗ ត្រូវមានការធ្វើជាកំណត់ហេតុ ហើយកំណត់ហេតុ ត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ។ ក្នុងករណីដែលចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថាខ្លួនបកប្រែឱ្យបានត្រឹមត្រូវ។ អ្នកបកប្រែមិនអាជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។ រាល់ការស្តាប់ចម្លើយទាំងឡាយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិ ចាំចាប់ត្រូវតែគោរពតាមមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ។ ក្នុងករណីដែលត្រូវរកអ្នកបកប្រែភាសា គឺសំដៅទៅលើបុគ្គលណាដែលគាត់ស្តាប់ការសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ អំពីភាសាជាតិមិនបាន និងមិនយល់ពីគ្នា ដោយយសារតែជាជនជាតិផ្សេងគ្នា ។

### ២.៨.ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក

នៅពេលដែលតុលាការបានទទួលនៅពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគលវត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យស្នើសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះ ពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ។

តាមបង្គាប់របស់ព្រះរាជអាជ្ញា ឱ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេត ទៅឱ្យម្ចាស់ដើមវិញក្នុងលក្ខខណ្ឌនៃការប្រគល់នោះមានដូចជា៖

- វត្ថុទាំងអស់នោះពុំមានប្រយោជន៍ដល់ការសំដែងការពិត
- ក្នុងករណីនេះប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដប្រជា

នៅក្នុងលក្ខខ័ណ្ឌនៃវត្ថុដែលមិនអាចប្រគល់ឱ្យវិញបានមានដូចជា:

- វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬ ទ្រព្យសម្បត្តិ
- វត្ថុដែលមានប្រយោជន៍សម្រាប់សំដែងការពិត
- វត្ថុដែលកាន់កាប់ដោយខុសច្បាប់ ដូចជាអាវុធ ឬជាតិផ្ទុះ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល។

## កថាខណ្ឌទី៣៖ ការបញ្ចប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលការស៊ើបអង្កេតមួយត្រូវបានធ្វើការសន្និដ្ឋានបញ្ចប់ហើយ នោះអ្នកដែលមានតួនាទីទទួលខុសត្រូវក្នុងរឿងក្តីនេះត្រូវធ្វើការសន្និដ្ឋាននូវការស៊ើបអង្កេត ត្រូវធ្វើរបាយការណ៍បញ្ចប់ការស៊ើបអង្កេត។ ការស៊ើបអង្កេតអាចឈានដល់ការបញ្ចប់ ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួន ហើយមានភស្តុតាងគ្រប់គ្រាន់ និងបង្ហាញថាអំពើដែលបានកើតឡើងនោះពិតជាបទល្មើសមួយប្រាកដមែន ហើយនៅក្នុងនោះដែលមានភស្តុតាងគ្រប់គ្រាន់អាចកំណត់បានថា អ្នកដែលប្រព្រឹត្តអំពើនោះគឺជាជនជាប់ចោទ ។ របាយការណ៍នេះ អាចត្រូវប្រាប់បញ្ចូលគ្នាដោយមានការសន្និដ្ឋានសរុបនូវរបាយការណ៍ស៊ើបអង្កេតបឋម និងរបាយការណ៍ស៊ើបអង្កេតជាក់ស្តែងបន្ថែមផ្សេងទៀត ។ ប៉ុន្តែអ្នកដែលមានកិច្ចស៊ើបអង្កេតក៏ត្រូវតែចង់ចាំដែរថា ការស៊ើបអង្កេតដែលចាប់ទុកថាចប់សព្វគ្រប់នោះ មិនចាំបាច់លុះត្រាតែធ្វើការចាប់ខ្លួន ជនល្មើសនោះទេ ។ តែទោះបីជាយ៉ាងណាក៏ការស៊ើបអង្កេតត្រូវបានបញ្ចប់ដែរ ទោះជាលទ្ធផលនៃការស៊ើបអង្កេតនោះមិនទាន់ចប់សព្វគ្រប់ក៏ដោយដូចជា៖

- ក្រោយពីបានប្រមូលភស្តុតាងទៅនគរបាលដើម្បីសន្និដ្ឋានថាអំពើនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ
- ជនល្មើសស្លាប់
- រឿងក្តីនោះជារឿងក្តី ឃាត់កម្ម និងអត្តឃាតរបស់ជនល្មើស
- ជនល្មើសសារភាពមុនពេលខ្លួនដាច់ខ្យល់ស្លាប់
- ការចាប់ខ្លួនរបស់ជនសង្ស័យ មិនត្រូវបានជនរងគ្រោះសហការគាំទ្រជាមួយ។

ជនសង្ស័យស្ថិតនៅក្នុងយុត្តាធិការផ្សេង ហើយពិបាកនឹងរកមធ្យោបាយនាំខ្លួនជននោះមកបាន ឬ ក៏អយ្យការយល់ថាការចំណាយដើម្បីនាំខ្លួនជននោះជាការចាំបាច់ជនដែលត្រូវបានចាប់ខ្លួននោះត្រូវបានអយ្យការចោទប្រកាន់លើបទល្មើសដែលនគរបាលចោទ ទាបជាងបទល្មើមុន ។

## កថាខណ្ឌទី៤៖ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីបានបញ្ចប់នៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែង ឱ្យមានសេរីភាពឡើងវិញដោយសេចក្តីសម្រចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។

ប្រសិនបើការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបញ្ចប់ជាស្ថាពរហើយ ព្រមទាំងតម្រុយភស្តុតាងស៊ីសង្វាក់គ្នាទៅវិញទៅមកនឹងបទល្មើស និងជនសង្ស័យព្រមទាំងផុតរយៈពេល នៃការឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនខ្លួនជននេះទៅកាន់អយ្យការ ។ ក្នុងរយៈពេលនៃការបញ្ជូនខ្លួននោះត្រូវគោរពតាមរយៈពេលនៃការបញ្ជូនខ្លួនដូចជា ៖

- បើបុគ្គលនោះត្រូវបញ្ជូនទៅអយ្យការ ជននោះត្រូវបញ្ជូនទៅភ្លាម
- បើមិនអាចបញ្ជូនដោយមូលហេតុលំបាកក្នុងការដឹកជញ្ជូន ព្រះរាជអាជ្ញាអាចផ្តល់រយៈពេលបន្ថែម
- ការបង្ហាញខ្លួនបុគ្គលឃាត់ខ្លួន ត្រូវធ្វើឡើងក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន
- កំណត់ហេតុអំពីការឃឹតយ៉ាវត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។[22]

ការជំនុំជម្រះផ្ទាល់ដែលគាត់ត្រូវតែគោរពបញ្ជារបស់ព្រះរាជអាជ្ញា និងត្រូវបំពេញកិច្ចនេះដូចមានចែងក្នុងមាត្រា ៤៦០ ដល់មាត្រា ៤៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា ។

### ៤.១ ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួន

ដោយយោងតាម ៣០៣ ( ការបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទដោយកម្លាំងអម ) និងមាត្រា៣០៤ ( នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យដឹងថា ជនជាប់ចោទត្រូវឃុំខ្លួនដោយកងការពាររហូតដល់សាមីខ្លួននៅមុខតុលាការដែលបង្ហាញខ្លួនត្រូវប្រព្រឹត្តទៅនៅថ្ងៃតែមួយ។ អត្ថន័យនៃកងការពារនៅទីនេះ គឺសំដៅទៅស្ថាប័នរបស់នគរបាលយុត្តិធម៌ ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញបេសកកម្មនេះ នៅក្នុងការអមជនជាប់ចោទដើម្បីចូលបង្ហាញខ្លួនចំពោះមុខតុលាការ ឬចៅក្រមជំនុំជម្រះ។

### ៤.២. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ

នៅក្នុងករណីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ គឺជាអ្នកអនុវត្តដីកាកោះហៅ ។ មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកដឹកនាំខ្លួនជនជប់ចោទទៅកាន់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬមណ្ឌលឃុំខ្លួន ឬពន្ធនាគារដើម្បីរក្សាទុកជាមុន រហូតដល់ពេលជននោះចូលបង្ហាញខ្លួន។

### ៤.៣. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនរយៈដីការបញ្ជូន ឬសាលដីការបញ្ជូន

[22] មាត្រា ១០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដោយយោងទៅតាមមាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា នៅក្នុងករណីដែលតុលាការទទួលពាក្យបណ្តឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ព្រះរាជអាជ្ញាត្រូវចាត់វិធានការចាំបាច់ ដើម្បីឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួន ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ ដែលក្នុងនេះក៏មានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ផងដែរ ។

## ៤.៤ ការធ្វើជាសាក្សីរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងនេះដែរប្រធានសវនាការ ធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថា មានប្រយោជន៍។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី នោះដោយយោងតាមមាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ៤.៥ ការធានាសណ្តាប់ធ្នាប់នៃសវនាការ

ការធានារ៉ាបរងនៅសណ្តាបធ្នាប់នៃសវនាការ ដែលជាតួនាទីរបស់ប្រធានសវនាការ។ ក៏ប៉ុន្តែប្រធានសវនាការអាចប្រើកម្លាំងសាធារណៈ ដែលអាចមាននគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការធ្វើជាជំនួយឱ្យស្ថាប័នរបស់តុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។[23]

## ៤.៦. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាកាអាចប្រគល់ឱ្យផងដែរ ដោយក្រឡាបញ្ជី តាមផ្លូវរដ្ឋបាលដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទដទៃផ្សេងទៀត ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលព្រះរាជអាជ្ញាសុំឱ្យជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា។ កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៦ ( ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគីដែលពាក់ព័ន្ធដោយអាជ្ញាសាលា ) ដល់មាត្រា ៤៨៨ ( ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬចៅសង្កាត់ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

## ៤.៧.ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

[23] មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការធ្វើពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ គឺមិនមែនគ្រាន់តែធ្វើនៅការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍ ដែលបានសម្រេចនូវសាលដីកានៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខព្រះរាជអាជ្ញានោះទេ តែក៏អាចធ្វើបាននៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលសំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ។ នៅពេលមានការប្តឹងបែបនេះជាលាយលក្ខណ៍អក្សរ ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលបណ្តឹងនោះទុកដើម្បីចាត់ការទៅតាមនីតិវិធី។

## ៤.៨ ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលប្រកាសសាលក្រម ចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលសំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។ កាលណាបើអង្គភាពនគរបាលយុត្តិធម៌បានទទួលពាក្យបណ្តឹងទាស់នោះ គាត់ត្រូវតែបញ្ជូនបណ្តឹងទាស់នេះទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រមនោះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាលើប្រធានបទស្តីពី **នីតិវិធីនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ** ទាំងមូលរួចមក យើងខ្ញុំសូមធ្វើការសន្និដ្ឋានដូចតទៅៈ

ក្រោយពីបានបញ្ចប់ការសិក្សាទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ដែលមានការតាក់តែងឡើងដោយអនុម័ត ពីអង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា រួចមក ធ្វើឱ្យពួកយើងខ្ញុំមានភាពយល់ដឹងបានច្រើនអំពី សមត្ថកិច្ច សិទ្ធិអំណាច និងតួនាទី របស់មន្ត្រីនគរបាលយុត្តិធម៌ និងនីតិវិធីនៃការស៊ើបអង្កេតទៅតាមមុខងាររបស់ខ្លួន។ តាមរយៈសារណានេះបានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងកិច្ចការងារ រវាងនគរបាលយុត្តិធម៌ព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរដែល ដែលមានភាពជាប់ប្រទាក់ក្រឡាគ្នាក្នុងការស៊ើបអង្កេតស្វែងរកការពិតនៃបទល្មើស។ ដូចនេះហើយ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ គឺមានគោលបំណងធ្វើយ៉ាងណាឱ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជន។ ហេតុដូចនេះ ទាមទារឱ្យមន្ត្រីដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតទាំងអស់ត្រូវតែបំពេញនូវមុខងាររបស់ខ្លួនឱ្យ បានត្រឹមត្រូវ និងគោរពទៅតាមបទបញ្ញត្តិ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ចាប់តាំងពីដំណាក់កាលដំបូងនៃការស៊ើបអង្កេតស្វែងរកបទល្មើស ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះ អាចបើកការស៊ើបអង្កេត ស្វែងរកភស្តុតាង និងដើម្បីឱ្យការពិតលេចចេញមក ដោយធ្វើការសាកសួរទៅកាន់ជនជាប់សង្ស័យ ឬក៏ដូចជាជនដែលជាប់ពាក់ព័ន្ធ និងធ្វើកំណត់ហេតុ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា។ នៅក្នុងដំណាក់កាលនោះដែលមន្ត្រីនគរបាលយុត្តិធម៌ គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត។ ហើយនៅក្នុងនេះផងដែលមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុ កសាងសំណុំរឿង បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនសំណុំរឿងជូនព្រះរាជអាជ្ញាដើម្បីធ្វើ ចំណាត់ការព្រមទាំងនាំខ្លួនជនជាប់សង្ស័យឱ្យទៅបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញាផងដែរ។ ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការទៅលើសំណុំរឿងដោយ តម្កល់រឿងទុកឥតចាត់ការ ឬសម្រេចធ្វើការចោទប្រកាន់ទៅលើជនល្មើស ដោយផ្អែកទៅលើមូលដ្ឋាននៃច្បាប់។ នៅក្នុងករណីនេះដែល ដើម្បីឱ្យដឹងការពិតនៃរឿងក្តី ថាបុគ្គលណាដែលបានប្រព្រឹត្តបទល្មើស បុគ្គលណាដែលមិនបានប្រព្រឹត្តបទល្មើស និងបុគ្គលណាដែលបានចូលរួមប្រព្រឹត្តបទល្មើស គឺត្រូវធ្វើការពិនិត្យទៅលើធាតុផ្សំនៃបទល្មើស ដែលធាតុផ្សំនៃបទល្មើស រួមមាន ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ដើម្បីធ្វើការថ្លឹងថ្លែង មុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ប៉ុន្តែក្នុងករណី បទមជ្ឈិម ឬបទលហុ ដែលតូចតាច ដោយព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងមានលក្ខណគ្រប់គ្រាន់អាចជំនុំជម្រះបាន ព្រះរាជអាជ្ញានឹងចេញដីកា

បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង។ ដោយឡែក សំណុំរឿងដែលមានភាពស្មុគស្មាញ មិនច្បាស់លាស់ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ ត្រូវមានភាពអព្យាក្រឹត្យក្នុងការស៊ើបសួរនឹងប្រមូលភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក ដើម្បីធានាឱ្យមានតុល្យាភាពរវាងការបង្ក្រាប និងគោរពសិទ្ធិជនត្រូវចោទ ព្រមទាំងលើកស្ទួយសិទ្ធិជនរងគ្រោះស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

សរុបមកនៅក្នុងនីតិវិធីនៃការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពិតជាមានសារសំខាន់ខ្លាំងណាស់ព្រោះ វាជានីតិវិធីដែលធ្វើឡើងដើម្បីស្វែងរកនៃការពិតនៃរឿងក្តីមុននឹងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ការស៊ើបអង្កេតនេះគឺត្រូវធ្វើឡើងយ៉ាងម៉ត់ចត់និងត្រឹមត្រូវក្នុងគោលបំណងធ្វើយ៉ាងណា ឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីស្វែងរកនូវការពិត ដោយយុត្តិធម៌ ដែលអាចធានាបាននូវការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ស្របទៅតាមបទបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី " នីតិវិធីនៃការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌ" ដែលបង្ហាញខាងលើនេះរួចមក ដើម្បីរួមចំណែកឱ្យប្រព័ន្ធច្បាប់ និងវិស័យយុត្តិធម៌ កាន់តែប្រសើរឡើង យើងខ្ញុំសូមផ្តល់ជាសំណូមពរ និងបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនមួយចំនួនដែលយល់ថាគួរធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើង ដើម្បីប្រកបដោយប្រសិទ្ធិភាពខ្ពស់នោះ យើងខ្ញុំសូមឱ្យក្រសួងយុត្តិធម៌ ឬ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងស្ថាប័នផ្សេងៗដែលទាក់ទងនឹងវិស័យច្បាប់ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ ពិនិត្យ និងអនុម័តច្បាប់ ដើម្បីឱ្យទាន់ពេលវេលា និងការវិវឌ្ឍប្រែប្រួលរបស់សង្គម។ បន្ថែមពីលើនេះទៅទៀត យើងខ្ញុំសូមអំពាវនាវទៅដល់អាជ្ញាធរមានសមត្ថកិច្ច ក្រសួង គ្រប់ជាន់គ្រប់ថ្នាក់ រួមទាំងរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវបទបញ្ញត្តិច្បាប់ផ្សេងៗ និងជួយធ្វើការកែរលម្អ និងសូមជួយបំពេញទៅលើចំណុចដែលខ្វះខាត ដែលមានដូចតទៅៈ

- ធ្វើការរៀបចំឱ្យមានការបណ្តុះបណ្តាលជំនាញ និងវិធីសាស្ត្រល្អៗ ក្នុងការស៊ើបអង្កេតដល់មន្ត្រីដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ដើម្បីធ្វើឱ្យការស៊ើបអង្កេតទទួលបានប្រសិទ្ធិភាពខ្ពស់ និងមានភាពច្បាស់លាស់ក្នុងការអនុវត្ត។
- ផ្តល់ជាសម្ភារៈ ឬឧបករណ៍បច្ចេកទេសសម្រាប់ធ្វើកោសល្យវិច្ច័យដល់មន្ត្រីដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត សម្រាប់ធ្វើការស្រាវជ្រាវស្វែងរកនូវភស្តុតាង ។
- ផ្តល់ប្រាក់ឧបត្ថមជាកញ្ចប់សម្រាប់បេសកកម្ម ដែលចុះធ្វើការស្រាវជ្រាវផ្សេងៗរបស់មន្ត្រីនគរបាល ក៏ដូចជាមន្ត្រីដែលជាប់ពាក់ព័ន្ធក្នុងការស៊ើបអង្កេត ដើម្បីធ្វើឱ្យការស៊ើបអង្កេតមានភាពសកម្ម ក៏ដូចជាការលើទឹកចិត្តដល់មន្ត្រី ដែលមានស្នាដៃក្នុងការបំពេញមុខងាររបស់ខ្លួនបានល្អ។
- ដំឡើងប្រាក់បៀវត្សឱ្យមន្ត្រីដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតឱ្យបានសមរម្យ ដើម្បីធ្វើឱ្យការបំពេញនូវមុខងារប្រកបដោយការទទួលខុសត្រូវខ្ពស់និងធ្វើការដាក់ពិន័យដល់មន្ត្រីណាដែលមិនគោរពនៅតួនាទី ក៏ដូចជាមុខងារភារកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត ។

ក្នុងករណីនេះព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរដោយផ្ទាល់ចៀសវាងឱ្យក្រឡាបញ្ជីជាអ្នកស៊ើបសួរជំនួស ជាពិសេសនោះ គឺត្រូវគោរពតួនាទីរបស់ខ្លួនទៅតាមបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ជាចុងក្រោយប្រសិនបើ ចំណុចទាំងអស់ខាងលើនេះត្រូវបានអនុវត្ត ក៏ដូចជាមានការបំពេញបន្ថែម ពិតជាល្អខ្លាំងណាស់។ ពួកយើងនិងជឿជាក់ថា ការស៊ើបអង្កេតស្វែងរកជនល្មើស និងទទួលបាននូវលទ្ធផលល្អ ហើយប្រជាពលរដ្ឋនឹងទទួលបាននូវភាព យុត្តិធម៌ ជាពិសេសជាងនេះទៅទៀតនោះគឺ សង្គមទទួលបាននូវភាពល្អប្រសើរ ដោយគ្មានការរំលោភសិទ្ធិគ្នា និងមានការកាត់បន្ថយនូវអំពើល្មើសក្នុងសង្គម ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅក្នុងសង្គមមានសុវត្ថិភាព សន្តិភាព និងប្រកបដោយភាពរីកចម្រើន។

# ឯកសារយោង

# ឯកសារយោង

## ១.បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩
- ច្បាប់ស្តីពី ព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២
- ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០០៥

## ២.ស្លាដែសៀវភៅ៖

- សៀវភៅ " នីតិវិធីព្រហ្មទណ្ឌរបស់មន្ត្រីនគរបាលយុត្តិធម៌ " ( អំណោយស្ថានទូតបារាំង ឆ្នាំ២០០៩ )
- សៀវភៅ គោលការណ៍ទូទៅ នៃ នីតិក្រមទាំងបួន ( ក្រោមស្នាដៃសាស្ត្រាចារ្យ លោក អាត ច័ន្ទដារា និង លោក សុង ប៊ុនឃៀង ឆ្នាំ២០១៤ )
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំសិក្សា២០១៣ = ២០១៤
- សៀភៅ " នគរបាលយុត្តិធម៌ " រៀបរៀងដោយ៖ សាស្ត្រាចារ្យ កៅ សីហា បោះពុម្ពផ្សាយឆ្នាំ ២០០៩ ( នៅរោងពុម្ព អង្គរ )
- " ដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌ សម្រាប់មន្ត្រីអនុវត្តច្បាប់នៅកម្ពុជា " រៀបរៀងដោយ៖ នាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ឆ្នាំ ២០១៩
- វីដេអូស្តីពី ' វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ 'ក្រោមការធ្វើបទបង្ហាញរបស់ឯកឧត្តម កើត រិទ្ធី អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ ចុះផ្សាព្វផ្សាយថ្ងៃទី ២០-២៤ ខែមិថុនា ឆ្នាំ២០១៦
- ប្រកាសស្តីពីរបៀបប្រកាសធ្វើការរបស់មន្ត្រីនគរបាលយុត្តិធម៌ របស់ក្រសួងយុត្តិធម៌ លេខ២៧ ប្រ.ក.រ.ប.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤
- សៀវភៅ ក្បួននីតិវិធីតុលាការ ឆ្នាំ២០០៧

## ៣.វចនានុក្រម៖

វចនានុក្រម សម្តេចសង្ឃ **ជួន ណាត** ។

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធទី១

- ❖ គំរូសញ្ញាប័ត្រនិងវិញ្ញាបនបត្រ
- • វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា
- • វិញ្ញាបនប័ត្រវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌
- • សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌
- ❖ ការធ្វើសម្បថ
- • ប្រកាសស្តីពី បែបបទនិងទម្រង់ការនៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌
- • នីតិវិធីនៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌
- • ពាក្យសច្ចាប្រណិធាន
- ❖ ក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់

## ២. ឧបសម្ព័ន្ធទី២

- ❖ បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ( មាត្រា១៨ និងមាត្រា១៩)
- ❖ គំរូលិខិតក្នុងនីតិវិធី
- • ពាក្យសុំដីកាឆែកឆេរសម្រាប់បទល្មើសមិនជាក់ស្តែង
- • កំណត់ហេតុនៃបទល្មើស
- • បញ្ជីវត្ថុតាងដែលចាប់យក
- • កំណត់ហេតុទទួលវត្ថុតាង
- • ដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់សង្ស័យ ឬជនល្មើសមកសួរចម្លើយ
- • ដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន ឬរុករកវត្ថុតាង
- • ដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ
- • ដីកាបង្គាប់ឱ្យចូលខ្លួន
- • ដីកាបង្គាប់ឱ្យនាំខ្លួន
- • ដីកាចាត់ឱ្យស៊ើបសួរជំនួស
- • លិខិតជូនដំណឹង

# ឧបសម្ព័ន្ធទី១

# គម្រូ

# សញ្ញាបត្រ

# និង

# វិញ្ញាបនបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាភូមិន្ទនគរបាល

# វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

## នាយកសាលាភូមិន្ទនគរបាល

## CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា:.................................................កើតថ្ងៃទី.....................................នៅ..........ភ្នំពេញ..........

**Certifie que**................................................ **né(e)le**.......................................... **à**..........Phnom Penh..........

បានរៀនវគ្គ..........បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌..........និទ្ទេស..............................នៅសាលាភូមិន្ទនគរបាល

**a suivi le starge**..........Classe de formation des Policiers Judiciers.......... **Mention**.............................. **à l'Ecole Royale de police**

ចាប់ពីថ្ងៃទី...២០....ខែ.....មិថុនា.......ឆ្នាំ២០០៧....ដល់ថ្ងៃទី..២២....ខែ......មិថុនា.....ឆ្នាំ២០០៧....។

**du**......................20 June 2007........................ **au**..........................22 June 2007..........................

វិញ្ញាបនប័ត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ, ថ្ងៃទី...២៨.....ខែសីហា...ឆ្នាំ២០០៧

លេខ:........................

**Phnom Penh, le**..........................................

**នាយកសាលាភូមិន្ទនគរបាល**

**Le directeur de l'Ecole Royale de Police**

ឧត្តមសេនីយ៍ឯក.ម៉ៅ_ឈឿន



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រ

## វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី ១៦

**មកពីនាម** : លោកវរសេនីយ៍ត្រី **ម៉ឹង សុខលុច** អត្តលេខ ១០៨ ៣៦៥

តួនាទីជំនួយការការិយាល័យសន្តិសុខ អ.ហ រាជធានី

**បានបញ្ចប់** : **វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ជំនាន់ទី ១៦**

ពីថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

**មេបញ្ជាការ**

លេខ:......៣៩..../ស.ស.រ.
/២០១១

**នាយឧត្តមសេនីយ៍ សៅ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ　　　　　　　　ក្រសួងយុត្តិធម៌

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ២៥៦/២០១១ ស.ណ.ក របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ស្តីពីមន្ត្រីកងរាជអាវុធហត្ថ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចមានចែងក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : លោក ម៉ាំង សុខលុច　កើតថ្ងៃទី 0៥ ខែ កក្កដា ឆ្នាំ ១៩៨០

ឋានន្តរសក្តិ : ចរសេនីយ៍ត្រី　អត្តលេខ ១០៨ ៣៦៥　មុខតំណែង ជំនួយការ ការិយាល័យសន្តិសុខ

អង្គភាព : មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សំរាប់ទទួល

សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : លោកចរសេនីយ៍ត្រី ម៉ាំង សុខលុច ទុកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១១　　　　រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១១

លេខ ០៧៣៩/១១ ន.ប.យ.ន.អ.ប

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ
ទាហានឧត្តមសេនីយ៍.ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អង្គ.វង្សវឌ្ឍនា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាភូមិន្ទនគរបាល

# វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

**នាយកសាលាភូមិន្ទនគរបាល**

## CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា:..................................................កើតថ្ងៃទី......................................នៅ.........................ភ្នំពេញ..................

**Certifie que**.................................................. **né(e)le**...................................... **à** ......................Phnom Penh..................

បានរៀនចប់វគ្គ..................បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌..............................និទ្ទេស..................................នៅសាលាភូមិន្ទនគរបាល

**a suivi le starge**...........Classe de formation des Policiers Judiciers.......... **Mention** ............................**à l'Ecole Royale de police**

ចាប់ពីថ្ងៃទី...២០....ខែ.....មិថុនា.......ឆ្នាំ២០០៧.....ដល់ថ្ងៃទី..២២....ខែ......មិថុនា.....ឆ្នាំ២០០៧....។

**du**..........................20 June 2007.......................... **au**..........................22 June 2007..........................

វិញ្ញាបនប័ត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ, ថ្ងៃទី..២៨.....ខែ[illegible]...ឆ្នាំ២០០៧

លេខ:.........................

**Phnom Penh, le**......................................

**នាយកសាលាភូមិន្ទនគរបាល**

**Le directeur de l'Ecole Royale de Police**

ឧត្តមសេនីយ៍ឯក.ម៉ៅ_ឈឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ **៩២១ ល.ស** របស់អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី **១១** ខែ **កញ្ញា** ឆ្នាំ ២០០៧ ស្តីពីមន្ត្រីនគរបាល ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : ______ កើតថ្ងៃទី ______ ខែ ______ ឆ្នាំ ______

ឋានន្តរស័ក្តិ ______ អត្តលេខ ______ ឋានៈ ______

មុខងារ : **នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌**

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល **សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌**

ចេញជូន : ______

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ: ៩.ប.ឃ.ន

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍនា

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

# ការធ្វើសម្បថ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ: ៣៤៤ ភយ.ប្រកស/០៧

រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧

# ប្រកាស

**ស្តីពី**

**បែបបទ និងនីតិវិធី នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

**សម្រេច**

**ប្រការ ១ :**

ត្រូវបានទទួលនូវគុណសម្បត្តិ ជាភ្នាក់ងារនគរបាលយុត្តិធម៌ ចំពោះមន្ត្រីនគរបាល កងរាជអាវុធហត្ថ យោធិនដែលចាំបាច់ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ :

១- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**ប្រការ ២ :**

មុននឹងបំពេញមុខងារ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង ទៅតាមបែបបទ និងរូបមន្ត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៣ :**

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៤ :**

ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងគ្រប់ខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

អង្គ វង្សវឌ្ឍនៈ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការ និងអយ្យការសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៥ កយ.ប្រក/ ០៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧*

## នីតិវិធី

## នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

១- ក្រឡាបញ្ជី ជាអ្នកចាត់តាំងកម្មវិធី :

- ហៅឈ្មោះអ្នកដែលចូលធ្វើសម្បថម្នាក់ម្តងៗ ចូលក្នុងសាលពិធី
- ប្រកាសបើកពិធីធ្វើសម្បថ ភ្នាក់ងារនគរបាលយុត្តិធម៌
- ប្រកាសសមាសភាព ក្រុមប្រឹក្សា តំណាងអយ្យការ និងក្រឡាបញ្ជី :

☞ តំណាងតុលាការ

- លោក.......................... ប្រធានសាលាដំបូង

☞ តំណាងអយ្យការ

- លោក.......................... ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

☞ ក្រឡាបញ្ជី

- លោក.......................... ក្រឡាបញ្ជីនៃពិធី

២- ក្រឡាបញ្ជីអានបញ្ជីឈ្មោះអ្នកដែលត្រូវស្បថ

៣- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

៤- តំណាងភ្នាក់ងារនគរបាលយុត្តិធម៌ម្នាក់ អាន **ទ្រោះព្ទទាន** ( ឱ្យអ្នកស្បថថាតាមខ្លាំងៗ )

៥- ប្រធានក្រុមប្រឹក្សា អាន **សច្ចាប្រណិធាន** ( ឱ្យអ្នកស្បថលើកដៃស្តាំដាក់ត្រឹមត្រចៀក និងថាតាមខ្លាំងៗ )

៦- មតិផ្តាំផ្ញើ របស់តំណាងអយ្យការ

៧- មតិផ្តាំផ្ញើ របស់ប្រធានក្រុមប្រឹក្សា

៨- ចប់កម្មវិធី

*__សំគាល់:__ អ្នកស្បថទាំងអស់ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងថតចំលងកំណត់ហេតុជូនសាមីខ្លួនម្នាក់ៗ*



# ប្រណិធាន (សេចក្តីអំពាវនាវ)

បពិត្រអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មាន : ព្រះអង្គជង្កើរ ព្រះអង្គក្រពុំឈូក ព្រះអង្គ ស្វេតច្ឆ័ត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវិតវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្វែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថ ត្បិតយើងខ្ញុំបានចូលខ្លួនមកសុំធ្វើសម្បថសច្ចាប្រណិធាន ដើម្បីបំពេញតួនាទីជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលនេះ ។

បើយើងខ្ញុំប្រព្រឹត្តល្មៀងឃ្លាងឃ្លាតចាកច្បាប់ មិនអនុវត្តត្រឹមត្រូវតាមច្បាប់ ដោយមានចេតនាទុច្ចរិត សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បំផ្លាញយើងខ្ញុំឱ្យវិនាសលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ឡានម៉ូតូបុក ខ្លាខាំ ពស់ចឹក លុះអានាគតជាតិ ឱ្យព្រាត់ប្រាស់ និរាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើយើងខ្ញុំប្រព្រឹត្តល្អទៀងត្រង់ ត្រឹមត្រូវតាមគន្លងច្បាប់ យកចិត្តទុកដាក់ប្រឹងប្រែងអនុវត្តការងារ ដោយស្មោះត្រង់ អស់ពីចិត្តពីថ្លើម សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោក ជួយឱ្យយើងខ្ញុំ មានអាយុវែងយឺនយូរ មានសេចក្តីសុខដុមរមនា មានសុខភាពល្អ មានទ្រព្យសម្បត្តិ មាស ប្រាក់ កែវកង ពិទូរ្យស្វរ្យកាន្ត សម្បូរហូរហៀរ លុះអនាគតជាតិ បានជួបតែសេចក្តីល្អ មានទ្រព្យស្តុកស្តម្ភ កិត្តិយសថ្លៃថ្នូរ ចម្រុងចម្រើន ថ្កុំថ្កើងរុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈ ជាភ្នាក់ងារនគរបាលយុត្តិធម៌របស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ ។

# ក្រមសីលធម៌សំរាប់មន្ត្រី
# ប្រតិបត្តិច្បាប់

# Code of Conduct for
# law Enforcement Officials

# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct for Law Enforcement Officials

អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩ ។

Adopted by General Assembly resolution 34/169 of 17 December 1979

## មាត្រា ១.-

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

**អត្ថាធិប្បាយ**

ក- ពាក្យថា "មន្ត្រីប្រតិបត្តិច្បាប់" សំដៅដល់មន្ត្រីទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវជ្រើសតាំងក្តីឱ្យតែប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋ មន្ត្រីទាំងឡាយដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេសនូវសេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច មូលហេតុសង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះជាបន្ទាន់ ។

ឃ- បញ្ញត្តិនេះមានគោលដៅធ្វើការទប់ស្កាត់ មិនត្រឹមតែអំពើហិង្សា អំពើសាហាវព្រៃផ្សៃ និងការធ្វើទុក្ខទោសដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងធ្វើការទប់ស្កាត់ចំពោះអំពើល្មើសផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។

## មាត្រា ២.-

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សានិងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

**អត្ថាធិប្បាយ**

ក- សិទ្ធិមនុស្សដូចមានចែងខាងលើ ត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងនោះមានលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួនដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូប កុំឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃពួកអាប៉ាថេដ អនុសញ្ញាអន្តរជាតិស្តីពីការបង្ការ

និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ហើយនិងមាន អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ- សេចក្តីអត្ថាធិប្បាយថ្នាក់ជាតិលើបញ្ញត្តិនេះ គួរបញ្ជាក់ថា ជាបទបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលបានទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣.-

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កំលាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតនៅក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

**អត្ថាធិប្បាយ**

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់អាចមានការលើកលែង មានន័យថា មន្ត្រីប្រតិបត្តិច្បាប់ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កំលាំងតាមការចាំបាច់ និងសមហេតុផល ដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ឬដើម្បីជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនសង្ស័យតាមច្បាប់ ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។

ខ- តាមធម្មតា ច្បាប់ជាតិនៃប្រទេសនីមួយៗ បានដាក់កំហិតយ៉ាងតឹងតែងដល់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការប្រើប្រាស់កំលាំងនេះ ដោយអនុលោមតាមគោលការណ៍សមាមាត្រ ។ គេក៏ត្រូវយល់ដែរថា គេត្រូវគោរពតាមគោលការណ៍ជាតិស្តីពីសមាមាត្រក្នុងការបកស្រាយបញ្ញត្តិនេះ ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការបកស្រាយបញ្ញត្តិនេះ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំង ដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយឡើយ ។

គ- ការប្រើប្រាស់អាវុធត្រូវបានគេចាត់ទុកថា ជាវិធានការមួយដែលខ្លាំងក្លាបំផុត ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវខំជៀសវាងការប្រើប្រាស់អាវុធ ជាពិសេសទៅលើអនីតិជន ។ ជាទូទៅ ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណាដែលការចាត់វិធានការមិនមានកំលាំងគ្រប់គ្រាន់ ដើម្បីបញ្ឈប់ ឬចាប់ខ្លួនជនល្មើស ។ ពេលណាដែលមានការបាញ់កាំភ្លើងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤.-

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសំងាត់ ហើយដែលឋិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែរក្សាទុកជាសំងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌ ។

**អត្ថាធិប្បាយ**

តាមប្រភេទការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលពត៌មាននានា ដែលអាចមានការទាក់ទងដល់ជីវិតរស់នៅផ្ទាល់ខ្លួន ឬដែលអាចបណ្តាលឱ្យខូចខាតដល់ប្រយោជន៍ជាសក្តានុពល ឬជាពិសេសប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការរក្សា និងការប្រើប្រាស់ព័ត៌មាននេះ ហើយពត៌មាននេះអាចលាតត្រដាងបាន

សំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថ៌កំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

## មាត្រា ៥.-

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ហាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួន ដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាមធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

**អត្ថាធិប្បាយ**

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ (អំពើនេះ) គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស (និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនឹងសិទ្ធិមនុស្ស) ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំនងឱ្យជននោះ ឬតតិយជនណាម្នាក់ ឱ្យផ្តល់ពត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើដែលជននោះបានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ដែលកើតមាន ដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងក៏រិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុងបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោសឡើយ" ។

គ- ចំពោះពាក្យថា "ការប្រព្រឹត្ត ឬការធ្វើទារុណកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬផ្លូវចិត្ត ។

## មាត្រា ៦.-

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

**អត្ថាធិប្បាយ**

សំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថិកំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

**មាត្រា ៥.-**

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ជាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួន ដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាមធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

**អត្ថាធិប្បាយ**

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ (អំពើនេះ) គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស (និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនឹងសិទ្ធិមនុស្ស) ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំនងឱ្យជននោះ ឬតតិយជនណាម្នាក់ ឱ្យផ្តល់ពត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើដែលជននោះបានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ដែលកើតមាន ដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងកំរិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុងបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោសឡើយ" ។

គ- ចំពោះពាក្យថា "ការប្រព្រឹត្ត ឬការធ្វើទារុណកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬផ្លូវចិត្ត ។

**មាត្រា ៦.-**

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

**អត្ថាធិប្បាយ**

ក- ការព្យាបាលជម្ងឺ "សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញវិជ្ជាជីវៈ និងគ្រូពេទ្យជំនួយ ដែលគ្រូពេទ្យទាំងនេះត្រូវធានាឱ្យមានជានិច្ចសំរាប់បំរើសេចក្តីត្រូវការ ។

ខ- ប្រសិនបើបុគ្គលិកផ្នែកសុខាភិបាលចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ហើយ មន្ត្រីប្រតិបត្តិច្បាប់ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលផ្នែកសុខាភិបាលទាំងនេះ នៅពេលដែលគេព្យាបាលជនដែលនៅក្នុងការឃុំគ្រងរបស់ខ្លួន តាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកសុខាភិបាលដែលមិនឋិតក្នុងកិច្ចប្រតិបត្តិការរបស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ- មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវធានាឱ្យមានការព្យាបាលសុខភាពដល់ជនរងគ្រោះ ដោយការរំលោភច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តរំលោភច្បាប់ផងដែរ ។

## មាត្រា ៧.-

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះឱ្យបានយ៉ាងខ្លាំងក្លា ។

**អត្ថាធិប្បាយ**

ក- អំពើពុករលួយ ក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋពីសំណាក់អាជ្ញាធរដែរ ហើយអំពើបែបនេះជាអំពើដែលផ្ទុយពីកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិច្បាប់ ។ មន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់ មកគ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើរដ្ឋាភិបាលមិនអាចអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬស្ថាប័នរបស់ខ្លួន ។

ខ- និយមន័យនៃពាក្យ "អំពើពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិ ។ ការរួមគំនិតប្រព្រឹត្តអំពើសូកប៉ាន់ផ្សេងៗ គឺជាបទល្មើសពុករលួយ ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាម ជាមន្ត្រីប្រតិបត្តិច្បាប់ បើមានការព្រងើយកន្តើយមិនបង្រ្កាបអំពើសូកប៉ាន់ឱ្យបានច្បាស់លាស់ទេ មន្ត្រីប្រតិបត្តិច្បាប់ ត្រូវចាត់ទុកថា បានឃុបឃិតក្នុងអំពើពុករលួយដែរ ។ ការទទួលអំណោយ (ជាវត្ថុ ឬជាប្រាក់) រង្វាន់លើកទឹកចិត្តផ្សេងៗ ការសន្យានានា ដែលមិនសមស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទល្មើសពុករលួយ ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវឆន្ទៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨.-

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យនេះ ហើយត្រូវទប់ស្កាត់នឹងប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណា ដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើ ហើយប្រសិនបើជាចាំបាច់ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

**អត្ថាធិប្បាយ**

ក- គេត្រូវតែគោរពតាមបទវិន័យនេះភ្លាម កាលណាបទវិន័យនេះបានត្រូវគេបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។ ប៉ុន្តែនៅប្រទេសខ្លះច្បាប់នីតិបញ្ញត្តិ ឬនីតិប្រតិបត្តិរបស់គេមានលក្ខណៈតឹងរឹងជាងបទវិន័យបច្ចុប្បន្ននេះទៅទៀត ។ ក្នុងករណីបែបនេះ មន្ត្រីប្រតិបត្តិច្បាប់ត្រូវតែគោរពតាមច្បាប់ដែលតឹងរឹងនោះ ។

ខ- មាត្រានេះ សំដៅធ្វើការថ្លឹងថ្លែងរវាងសេចក្តីត្រូវការឱ្យមានគោលសំខាន់ពីរ គោលសំខាន់ទី១ គឺការរក្សា និងការពង្រឹងវិន័យផ្ទៃក្នុងរបស់ស្ថាប័ន ដើម្បីជាប្រយោជន៍ដ៏ទូលំទូលាយដល់សន្តិសុខសាធារណៈ ។ គោលសំខាន់ទី២ គឺការបង្ការ និងការការពារកុំឱ្យមានអំពើរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ បើមានការរំលោភច្បាប់មន្ត្រីប្រតិបត្តិច្បាប់ត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅនាយចៅហ្វាយតាមលំដាប់ឋានានុក្រម ។ ដរាបណាស្ថាប័នរបស់ខ្លួនបានប្រើគ្រប់មធ្យោបាយហើយនៅតែគ្មានប្រសិទ្ធភាព ដរាបនោះមន្ត្រីប្រតិបត្តិច្បាប់ អាចរាយការណ៍អំពីរឿងរំលោភច្បាប់នេះ ទៅស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីការរំលោភលើបទវិន័យ ឬអំពីគំរោងផែនការ នៃការប្រព្រឹត្តអំពើពុករលួយណាមួយ អ្នករាយការណ៍ (មន្ត្រីប្រតិបត្តិច្បាប់) មិនត្រូវបាន ទទួលទណ្ឌកម្ម ឬដាក់វិន័យរដ្ឋបាលណាមួយពីស្ថាប័នរបស់ខ្លួនឡើយ ។

គ- ពាក្យថា "អាជ្ញាធរមានសមត្ថកិច្ច ឬអង្គការរដ្ឋដែលមានអំណាចពិនិត្យ និងដោះស្រាយ" សំដៅដល់អាជ្ញាធរ ឬអង្គការរដ្ឋដែលស្ថិតនៅក្នុងរង្វង់នៃច្បាប់ជាតិ ទោះជាអាជ្ញាធរ ឬអង្គការរដ្ឋនោះនៅក្នុង ឬឯករាជ្យពីស្ថាប័នប្រតិបត្តិច្បាប់នោះក៏ដោយ ដែលមានអំណាចតាមលក្ខខណ្ឌអំណាចតាមទម្លាប់ ឬអំណាចផ្សេងៗទៀត ក្នុងការពិនិត្យលើបណ្តឹងសារទុក្ខ ឬបណ្តឹងផ្សេងទៀតអំពីការរំលោភបំពានច្បាប់នៅក្នុងរង្វង់ព្រំដែននៃបទវិន័យនេះ ។

ឃ- នៅប្រទេសខ្លះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់បែបយ៉ាង ត្រូវបានគេចាត់ទុកថាបានបំពេញភារកិច្ចក្នុងការពិនិត្យសើរើពាក្យបណ្តឹងនានា ប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចដែលបានរៀបរាប់នៅក្នុងវគ្គ (គ) ខាងលើ ។

ង- ដើម្បីទាក់ទាញមតិសាធារណជន ឱ្យចេះឈឺឆ្អាលក្នុងរឿងរំលោភច្បាប់នេះ ភ្នាក់ងារក្រសួងការពារច្បាប់អាចផ្សព្វផ្សាយតាមរយៈ វិទ្យុ ទូរទស្សន៍ ភាពយន្ត ល្ខោន ទស្សនាវដ្តី ឬកាសែតក៏បាន ឱ្យតែគេអាចបញ្ជាក់ហេតុផលថា គេបានអនុលោមទៅតាមច្បាប់ទម្លាប់របស់ប្រទេសគេ និងគោរពតាមបញ្ញត្តិនៃមាត្រាទី៤ ក្នុងបទវិន័យនេះ ។ ប៉ុន្តែការប្រើតាមមធ្យោបាយខាងលើនេះ អាចប្រើបានតែក្នុង ដំណាក់កាលចុងក្រោយបំផុតប៉ុណ្ណោះ ប្រសិនបើគ្រប់មធ្យោបាយឯទៀតដែលគេបានប្រើរួចមកហើយនោះ ពុំបានសំរេចដូចបំណង ។

ច- ភ្នាក់ងារក្រសួងការពារច្បាប់ទាំងឡាយណា ដែលបានគោរពច្បាប់នៃបទវិន័យនេះ តែងតែបានទទួលនូវការគោរពស្ងើចសរសើរ ការគាំទ្រ ព្រមទាំងការរួមសហប្រតិបត្តិការពីសំណាក់សហគមន៍ ពីសំណាក់ស្ថាប័នអនុវត្តន៍ច្បាប់ និងពីសំណាក់អ្នកដែលមានអាជីពក្នុងវិស័យប្រតិបត្តិច្បាប់ ។

RULE

# ឧបសម្ព័ន្ធទី២

**UNITED NATIONS**
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA
(UNTAC)

**NATIONS UNIES**
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE
(APRONUC)

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល




*PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD*

*DISPOSITIONS RELATIVES AU SYSTEME JUDICIAIRE AU DROIT PENAL ET ALA PROCEDURE PENALE APPLICABLES AU CAMBODGE PENDANTLA PERIODE TRANSITOIRE*

## មាត្រា ១៨ : បទល្មើសជាក់ស្តែង

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺថា ៖

- បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប្រជាប់ចាប់ប្រភឹង
- បើជនសង្ស័យត្រូវបានសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ បទល្មើស ថាជាពិរុទ្ធិកជន
- បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ។

## មាត្រា ១៩ : ការចាប់ខ្លួនដោយសំអាងលើភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់

១ : ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបាន លុះត្រាតែមានភ័ស្តុតាងជាក់ស្តែងយ៉ាងខ្លាំង, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញអោយឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទបញ្ជីមមែន ។

២ : បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា ឬ ចៅក្រម ដែលនឹងត្រូវអនុវត្តដោយនគរបាលតុលាការ ។

៣ : ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយ ដែលនាំអោយមានការចាប់ខ្លួនជនជាប់សង្ស័យនោះ ។

៤ : ជោគវាសនារបស់ជនដែលត្រូវគេចាប់ខ្លួន ត្រូវបានចាត់ចែង តាមលក្ខខ័ណ្ឌនៅក្នុងមាត្រា១៣ នៃបទបញ្ញត្តិនេះ ។

៥ : ម្យ៉ាងទៀត តាមដីកាបង្គាប់អោយឡើងសាលារបស់រដ្ឋអាជ្ញា ឬ ចៅក្រម នគរបាលអាចនាំខ្លួនជនគ្រប់រូប ដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកាកោះ មកបង្ហាញខ្លួនចំពោះមុខនាយនគរបាល ឬចៅក្រម ឬរដ្ឋអាជ្ញា។ ក្រោយពីតុលាការបានសាកសួរហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់ លើកលែងតែក្នុងករណីមានភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី ១៣ នៃបទបញ្ញត្តិនេះ ។

# គម្រូលិខិតក្នុងនីតិវិធី

ឧបសម្ព័ន្ធ ១០ (ខ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
.................................................................................(១)

សំណុំរឿងលេខ ...........................
លេខ ........................................

## ពាក្យសុំដីកាឆែកឆេរសម្រាប់បទល្មើសមិនជាក់ស្តែង(២)

យើង.......................................... ឋានៈ: ............... ...........................................
ជាមន្ត្រីអធិការកិច្ចថ្នាក់កសិកម្មនិងជីកសិកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃអង្គភាព(១)
.......................................................................... នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
យោងតាមលិខិតបញ្ជាបេសកកម្មលេខ ...................... ចុះថ្ងៃទី........ខែ............. ឆ្នាំ២០....
ចេញដោយ.........................................................................................................

### សូមគោរពជូន

**លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង**.......................................
**កម្មវត្ថុ៖** សំណើសុំដីកនាំការឆែកឆេរ.........................................................................
របស់ឈ្មោះ:.......................................ភេទ............អាយុ..............ឆ្នាំ សញ្ជាតិ..................
ទីលំនៅបច្ចុប្បន្ន៖..............................................................................................
មុខរបរ...........................................................................................................
**យោង**(៣)**៖** ................................................................................................
......................................................................................................................

